**រាជរដ្ឋាភិបាលកម្ពុជា**

*ក្រសួងមហាផ្ទៃ*

**អគ្គលេខាធិការដ្ឋាន**

**ការប្រញាប់**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# កំណត់បង្ហាញលិខិតចូល

**ក្រសួង ខេត្ត ក្រុង ផ្ញើ** គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា **លេខ** ០៧០ កសមក **ចុះថ្ងៃទី** ២៣.ឧសភា.២០២៣

**កម្មវត្ថុ:** សំណើសុំចាត់តំណាង ១រូប ចូលរួមជាវាគ្មិន និងមន្ត្រីជំនាញ ១រូប ចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ស្តីពី «ការតាមដានលើសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លើរបាយការណ៍តាមកាលកំណត់លើកទី៣ ស្តីពីយេនឌ័រ» នៃការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០២៣ និងសូមអញ្ជើញចូលរួមប្រជុំត្រៀម នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ វេលា៨:៣០ នាទីព្រឹក។

**ខ្លឹមសារសង្ខេប**:

សូមគោរពជូន លោកប្រធាននាយកដ្ឋានមេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់

**យោបល់អនុរដ្ឋលេខាធិការទទួលបន្ទុក**

[illegible handwriting]

រាជធានីភ្នំពេញ,ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០២៣

X. ប្រធានការិយាល័យរបៀប

ជឿង_រ៉ាន

**យោបល់រដ្ឋលេខាធិការទទួលបន្ទុក**

[illegible handwriting] 24.05.23

សក់_សេដ្ឋា

26-05-2023

ប៊ុន_ហុន

សក់_សេដ្ឋា ៨. **យោបល់នាយកដ្ឋាន**

[illegible handwriting] 24.05.23

ឧត្តមសេនីយ៍ឯក.ជុំ.សារ៉ាត់

**យោបល់ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**យោបល់អគ្គលេខាធិការ**

សូមគោរពជូន: ឯកឧត្តម រដ្ឋលេខាធិការប្រចាំការ ដើម្បីពិនិត្យ និង សម្រេចដ៏ខ្ពង់ខ្ពស់។

-គូរជូនឯកឧត្តម ប៊ុន ហុន រដ្ឋលេខាធិការ និងអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីជូនជាសមត្ថកិច្ច។

ដោយគោរពដ៏ខ្ពង់ខ្ពស់!

24.05.23

ម៉ែន ប៊ុនថ្លៃ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា
លេខ:......០៧០.........គ.ស.ម.ក

ក្រសួងមហាផ្ទៃ
អគ្គលេខាធិការដ្ឋាន
ចូល លេខ 532
ថ្ងៃ 23-05-23 17h00
ហត្ថលេខា..........

ថ្ងៃអង្គារ ៤ កើត ខែជេស្ឋ ឆ្នាំថោះ ចត្វាស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឧសភា ឆ្នាំ២០២៣

**សូមគោរពជូន**

**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**កម្មវត្ថុ:** សំណើសុំចាត់តំណាង ១រូប ចូលរួមជាវាគ្មិន និងមន្ត្រីជំនាញ ១រូប ចូលរួមក្នុងកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិលស្តីពី "**ការតាមដានលើសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លើរបាយការណ៍តាមកាលកំណត់លើកទី៣ ស្តីពីយែនឌ័រ**" នៃការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ នៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា កម្ពុជាបានការពាររបាយការណ៍ជាតិជុំទី៣ ស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (ICCPR) នាកិច្ចប្រជុំលើកទី៣៨៥០ ទី៣៨៥២ និងទី៣៨៥៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស (សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ) របស់អង្គការសហប្រជាជាតិ កាលពីថ្ងៃទី៩-១១ ខែមីនា ឆ្នាំ២០២២។ គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ បានអនុម័តនូវសេចក្តីសង្កេតសន្និដ្ឋាន (Concluding Observations) ចំនួន ១០ទំព័រ នៅកិច្ចប្រជុំលើកទី៣៨៦៨ និងទី៣៨៧០ នាថ្ងៃទី២២-២៣ ខែមីនា ឆ្នាំ២០២២ និងបានចេញផ្សាយនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ ដែលតម្រូវឱ្យកម្ពុជាបន្តអនុវត្តឆ្លើយតបទៅនឹងសេចក្តីសង្កេតសន្និដ្ឋានទាំងនោះ។

ដើម្បីធ្វើការផ្សព្វផ្សាយជូនក្រសួង ស្ថាប័ន និងអង្គការសង្គមស៊ីវិល អំពីសេចក្តីសង្កេតសន្និដ្ឋានទាំងនោះ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.) សហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា (OHCHR) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ *"សេចក្តីសង្កេតសន្និដ្ឋាននៃរបាយការណ៍តាមកាលកំណត់ជុំទី៣របស់កម្ពុជា ស្តីពីការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ"* កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២២ កន្លងមកនេះ។

គ.ស.ម.ក. និង OHCHR នឹងបន្តរៀបចំកិច្ចពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល ដោយផ្តោតលើប្រធានបទជាក់លាក់ ដែលកិច្ចពិគ្រោះយោបល់លើកដំបូងនេះស្តីពី "**ការតាមដានលើសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លើរបាយការណ៍តាមកាលកំណត់លើកទី៣ ស្តីពីយែនឌ័រ**" នៃការអនុវត្តកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលនឹងរៀបចំធ្វើនៅថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ (ទីកន្លែងនឹងគោរពជម្រាបជូនតាមក្រោយ)។

អាស្រ័យហេតុនេះ គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជាសូមគោរពស្នើសុំ **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាចាត់តំណាង ១រូប ឱ្យចូលរួមជាវាគ្មិន និងមន្ត្រីជំនាញ ១រូប ចូលរួមក្នុងកិច្ចពិគ្រោះខាងលើដោយអនុគ្រោះ។ វាគ្មិនតំណាងក្រសួងមហាផ្ទៃ នឹងត្រូវធ្វើបទបង្ហាញឬបទអន្តរាគមន៍ (យ៉ាងយូរ ១៥នាទី) ស្តីពី ...

អគារលេខ៣ ផ្លូវ VI 13, ភូមិទួលសំពៅ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ Tel : (855) 23 882 065
No. 3, St. VI 13, Toul Sampov Village, Sangkat Toul Sangke, Khan Russey Keo, Phnom Penh.
www.chrc.gov.kh Email: info@chrc.gov.kh

"ផែនការអនុវត្តសេចក្តីសង្កេតសន្និដ្ឋានក្នុងសមត្ថកិច្ចរបស់ក្រសួង" ដោយផ្តោតសំខាន់លើផែនការយុទ្ធសាស្ត្រ ក៏ដូចជាក្របខណ្ឌច្បាប់នានា ពាក់ព័ន្ធនឹងយែនឌ័រ។

គ.ស.ម.ក. ស្នើគោរពអញ្ជើញវាគ្មិនមកចូលរួមប្រជុំ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៣ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីពិភាក្សាត្រៀមមុនថ្ងៃរៀបចំកិច្ចពិគ្រោះយោបល់។

សូម **សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ ពីខ្ញុំបាទ៕

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា**

**កែវ_រ៉េមី**

*សូមគោរពជូនភ្ជាប់*
ឯកសារទស្សនទាន
សេចក្តីសង្កេតសន្និដ្ឋាន ICCPR ជាភាសាខ្មែរ និងអង់គ្លេស

*សូមទំនាក់ទំនងព័ត៌មាន*
ឯកឧត្តម អ៊ិត សាន (ទូរសព្ទ/តេឡេក្រាម ០៩៥ ៨៨១ ៩៥៣)
លោក ជឹម ធឿន (ទូរសព្ទ/តេឡេក្រាម ០១៦ ៣៧៦ ៧០៩)

**CONCEPT NOTE & AGENDA**
**Second Consultation with civil society on the follow up to the Concluding Observations of the Human Rights Committee on the Third Periodic Report of Cambodia – Gender**

**9 June 2023**

Location: TBC

## I. Background

1. Cambodia ratified the International Covenant on Civil and Political Rights (ICCPR) on 26 May 1992. Pursuant to article 40 of the Covenant, Cambodia submitted its first report to the Human Rights Committee (the Committee) on 23 September 1998. The report was reviewed on 27 July 1999. The second report was submitted in September 2012 and the review was conducted on 31 March 2015. The third report, which was submitted on 2 April 2019, was reviewed by the Committee in March 2022 and Concluding Observations issued on 18 May 2022.

2. In its Concluding Observations, the Committee called upon the State of Cambodia to widely disseminate the Covenant, its third periodic report and the present Concluding Observations with a view to raising awareness of the rights enshrined in the Covenant among the judicial, legislative and administrative authorities, civil society and non-governmental organizations operating in the country and the general public. As a step towards ensuring the dissemination and follow up on the implementation of the Concluding Observations, the Cambodian Human Rights Committee (CHRC), in collaboration with the Office of the United Nations High Commissioner for Human Rights (OHCHR) in Cambodia organized a joint workshop in November 2022, on the dissemination and implementation plan of the Concluding Observations of the Committee.

3. In line with ensuring the follow up to the implementation of the Concluding Observations and as a follow-up to the joint dissemination and implementation workshop of November 2022, CHRC will organize a series of consultations with civil society on the follow up to the implementation of recommendations.

4. Considering that gender continues to feature in many of the recommendations[1] addressed to Cambodia by treaty bodies and taking into account the necessity to ensure gender

[1] Including by the Committee on the Elimination of Discrimination against Women (CEDAW) (CEDAW/C/KHM/CO/6), the Committee on Economic, Social and Cultural Rights (CESCR), (E/C.12/KHM/CO/2, 27 March 2023), and recommendations by the Universal Periodic Review (UPR) (A/HRC/41/17, A/HRC/41/17/Add.1).

equality, including through commitment of Cambodia to the sustainable development goals (SDGs), gender equality has been prioritized as the thematic recommendations in the Concluding Observations to be addressed in the upcoming dissemination and implementation workshop.

## II. Objectives:

The objectives of the dissemination and implementation workshop on gender equality will be to:

- Discuss the implementation plan of relevant line ministries in relation to the implementation of the Concluding Observations of the Human Rights Committee, specifically in the area of gender equality, taking into account the Committee's previous recommendation on gender-based violence,
- Identify roles and discuss the responsibility of civil society organizations (CSOs), United Nations agencies and other relevant stakeholders in supporting the implementation plan of the relevant line ministries and
- Discuss next steps in relation to the dissemination and implementation plan, including prioritization of thematic recommendations to be addressed and joint activities, including awareness-raising campaigns that could be organized by ministries, CSOs, and UN entities.

## III. Participants:

- 20 participants from relevant ministries
- 15 participants from CSOs
- UNCT

**Agenda**

| **Time** | **Activity** | **Responsibility** |
|---|---|---|
| 7:30-8:30 | Arrival of all participants | |
| 8:30-8:35 | Introduction and National Anthem | |
| 8:35-8:40 | **Welcome Remarks** | ➢ Welcome remarks by Roueida El Hage, OHCHR Country Representative<br>➢ Welcome remarks by Ms. Camilla M Ottosson, Head of Section Office, Embassy of Sweden Section Office in Phnom Penh (TBC)<br>➢ Welcome remarks by H.E Dr. Ing Kanthaphavi, Minister of Women Affairs (TBC)<br>➢ Opening remarks by H.E. Mr. Keo Remy, Minister Delegate attached to the Prime Minister and Chairperson of the Cambodian Human Rights |

| | | |
|---|---|---|
| | | Committee (CHRC) |
| 8:40-9:00 | **Overview of the Concluding Observations related to Gender Equality**<br><br>Followed by Q&A | ➢ CHRC |
| 9:00-10:00 | **Implementation plan from ministries** | ➢ Ministry of Women Affairs, Cambodian National Council for Women (TBC)<br>➢ Ministry of Justice (TBC)<br>➢ Ministry of Interior (TBC)<br>➢ Ministry of Information |
| 10:00-10:15 | ➢ Coffee break | |
| 10:15-11:15 | **Contribution of the Civil Society in the implementation of the Concluding Observations** | ➢ SILAKA (TBC)<br>➢ GAD/C (TBC)<br>➢ NGO CEDAW (TBC) |
| 11:15-12:00 | **Group discussion** | Everyone |
| 12:00-12:10 | **Closing Remarks** | ➢ CHRC |
| 12:10 | Lunch will be provided | |

**VI. Annex (recommendations by the Committee and other relevant related gender recommendations by international human rights mechanisms).**

*Concluding observations on the third periodic report of Cambodia of the Human Rights Committee (CCPR/C/KHM/CO/3, 18 May 2022)*

| **Thematic** | **Recommendations** | **Paragraph** |
|---|---|---|
| Gender Equality | Ensuring that legislation and policies on gender equality are effectively implemented and reviewing the Labour Law of 1997 with a view to ensuring the implementation of the principle of equal pay for work of equal value and guaranteeing the full protection of domestic workers. | Para. 17 (a) |
| | Raising public awareness of the principle of equality between women and men and the need to eliminate gender stereotypes and ensuring that media outlets promote positive images of women as active participants in public and political life. | Para. 17 (b) |
| | Intensifying its efforts to achieve, within specific time frames, the full and equal participation of women in political and public life, including in the National Assembly, ministerial positions, regional and local municipalities, and the judiciary, particularly in decision-making positions | Para. 17 (c) |
| Violence Against Women (VAW) | Recalling the Committee's previous recommendation on gender-based violence, the State party should take steps to ensure that the Law on the Prevention of Domestic Violence and the Protection of Victims of 2005 is reviewed and amended to comprehensively define and criminalize domestic violence and to ensure effective investigations in line with the Covenant and other international standards. | Para. 19 |
| | The State party should also ensure that cases of violence against women are thoroughly investigated, that perpetrators are prosecuted and, if convicted, commensurate penalties are imposed, and that victims have access to effective remedies, receive full reparation, including adequate compensation, and have access to adequate protection and assistance. | Para. 19 |
| | It should continue conducting awareness-raising campaigns on violence against women for the public and ensure that functionaries in the legal system, including judges, prosecutors and law enforcement officers, receive appropriate training in this regard. | Para. 19 |

*UPR Recommendation on Gender (A/HRC/41/17, A/HRC/41/17/Add.1)*

| | |
|---|---|
| **Laws and Policies to address discrimination based on gender** | 110.49 Strengthen the land policy approved in 2015, which established that gender equality and equity between men and women should be ensured in the land registration process (Plurinational State of Bolivia);<br><br>110.50 Adopt, in consultation with civil society organizations, comprehensive legislation and policies against discrimination and violence based on sexual orientation or gender identity, and guarantee their implementation through all public entities, in particular in the education, health and labour sectors (Mexico);<br><br>110.172 Abolish the discriminatory prohibition on women from remarrying within 120 days of a divorce or annulment (Iceland);<br><br>110.185 Reform national legislation with a view to strengthening the protection of women and children against domestic violence (Russian Federation); |
| **Measures to Address Gender based violence** | 110.132 Overcome obstacles to access to justice for women victims of violence (Iraq);<br><br>110.179 Ensure efforts to eliminate all forms of gender-based violence and discrimination, and ensure empowerment of all vulnerable groups (Nepal);<br><br>110.180 Strengthen efforts to protect the rights of the most vulnerable groups, such as women, children and persons with disabilities, also in order to prevent and combat child labour and sexual exploitation, as well as other forms of violence, including domestic violence (Italy);<br><br>110.182 Provide mandatory training on prosecution procedures for cases of gender-based violence for law enforcement and judicial officers (Republic of Moldova);<br><br>110.183 Allocate sufficient human and financial resources to establish at least five one-stop service centres by 2024, to provide support services free of charge to victims of gender-based violence (Australia);<br><br>110.184 Conduct comprehensive investigations of cases of domestic and sexual violence, and ensure that perpetrators are prosecuted and victims are adequately compensated (Republic of Moldova); |

| | |
|---|---|
| **Women Empowerment & Raising Awareness** | 110.173 Continue ongoing mechanisms for gender parity and women's empowerment (India);<br><br>110.174 Continue to implement the gender equality policy to ensure gender mainstreaming in all sectors and programmes (Pakistan);<br><br>110.175 Further strengthen programmes to address discrimination against women and girls, and to promote gender equality (Philippines);<br><br>110.176 Continue to implement the gender equality policy by mainstreaming gender in all sectors and programmes (Lao People's Democratic Republic);<br><br>110.177 Redouble efforts to eradicate discrimination against women in the legal sphere and put an end to harmful practices and discriminatory stereotypes of which Cambodian women are victims (Uruguay);<br><br>110.178 Continue to step up measures aimed at promoting women's rights, including the elimination of all forms of discrimination and violence against women (Maldives);<br><br>110.181 Strengthen the role and status of women, and promote and protect the rights of children and persons with disabilities in society (Lao People's Democratic Republic); |

*Concluding observations on the sixth periodic report of Cambodia of the Committee on the Elimination of Discrimination against Women (CEDAW/C/KHM/CO/6, 12 November 2019)*

| **Thematic** | **Recommendations** |
|---|---|
| Legislative framework | 9. The Committee recommends that the State party:<br><br>(a) Ensure that its national legislation includes a definition of discrimination against women, covering direct and indirect discrimination in the public and private spheres, including intersecting forms of discrimination, in line with article 1 of the Convention, as accepted by the State party following its third universal periodic review (A/HRC/41/17/Add.1, para. 2);<br><br>(b) Systematically undertake gender impact assessments when adopting or revising laws, and ensure that legislative changes help to promote and protect the rights of women. |
| Access to justice and remedies | 11. Recalling its general recommendation No. 33 (2015) on women's access to justice, the Committee recommends that the State party:<br><br>(a) Develop a comprehensive legal aid scheme with sustainable, long-term funding from the national budget and establish regional appeals courts outside of the capital to ensure effective access to courts and |

| | |
|---|---|
| | tribunals by all women, particularly rural women, indigenous women, women belonging to ethnic minority groups and women with disabilities;<br>(b) Eliminate the stigmatization of women and girls who submit complaints about violations of their rights by raising awareness among the general public of those rights;<br>(c) Disseminate information on the mechanisms and procedures for seeking remedies for violations of the rights of women and girls, particularly in rural areas;<br>(d) Strengthen the gender responsiveness and gender sensitivity of the justice system, including by increasing the number of women in the judiciary and providing systematic capacity-building to judges, prosecutors, police officers and other law enforcement officials on the Convention, as well as on the Committee's concluding observations, its jurisprudence under the Optional Protocol and its general recommendations;<br>(e) Take specific steps to strengthen the independence and impartiality of the judiciary and ensure that cases of gender-based discrimination and violence against women, including domestic violence and rape, are thoroughly investigated, perpetrators are prosecuted and adequately punished and victims are provided with remedies;<br>(f) Strengthen measures to combat corruption, including by adopting and implementing effective disciplinary measures to hold government officials accountable for corruption, in order to restore women's trust in the justice system. |
| National machinery for the advancement of women | 15. The Committee recommends that the State party:<br>(a) Ensure that the Cambodian National Council for Women has the autonomy, authority and human, technical and financial resources necessary to effectively function as the national machinery for the advancement of women;<br>(b) Allocate sufficient resources and funding from the national budget for the implementation of action plans and policies for gender equality, including the fifth national strategic plan for gender equality and the empowerment of women (2019–2023);<br>(c) Ensure the full and effective participation of civil society organizations, including women's rights organizations, in the process of formulating the first national gender policy;<br>(d) Establish effective evaluation and monitoring mechanisms for all action plans, strategies and measures adopted to advance gender equality, as well as for activities undertaken by various ministries to promote gender equality, in order to measure progress and impact. |
| National human rights | 17. The Committee recommends that the State party expedite the process of establishing a national human rights institution in accordance with the |

| | |
|---|---|
| institution | principles relating to the status of national institutions for the promotion and protection of human rights (the Paris Principles), as accepted by the State party following its third universal periodic review (A/HRC/41/17/Add.1, para. 2), with a strong mandate to promote and protect women's rights and to ensure that the views and opinions of civil society organizations are effectively taken into account in this process. |
| Women human rights defenders, civil society and non-governmental organizations | 19. The Committee recommends that the State party fully guarantee the rights of women human rights defenders, trade union leaders, land and environmental activists and members of the political opposition party, particularly their rights to freedom of expression, assembly and association, without harassment, surveillance or other undue restrictions. |
| Temporary special measures | 21. Recalling its general recommendation No. 25 (2004) on temporary special measures, the Committee recommends that the State party adopt temporary special measures, including legislative, executive, administrative and other regulatory instruments, policies and practices, allocation and/or reallocation of resources, preferential treatment, targeted recruitment, hiring and promotion, and quota systems, to accelerate the achievement of substantive equality of women and men in all areas in which women are underrepresented or disadvantaged, targeting women in disadvantaged situations, such as women with disabilities, women belonging to ethnic minority groups, indigenous women, rural women and older women. It further recommends that the State party adopt such temporary special measures:<br>(a) To reallocate and distribute land so that women have equal ownership of land;<br>(b) To increase tenure security for women living in informal settlements and to improve access by women, especially indigenous women, women belonging to ethnic minority groups and rural women, to adequate housing including through the mechanisms established under the national housing policy;<br>(c) To increase economic opportunities for women in rural areas, including through the adoption of quotas. |
| Discriminatory gender stereotypes | 23. The Committee recommends that the State party:<br>(a) Adopt a comprehensive strategy with proactive and sustained measures that target women and men at all levels of society to eliminate discriminatory stereotypes and patriarchal attitudes concerning the roles and responsibilities of women and men in the family and society;<br>(b) Ensure that references to the Chbab Srey are fully eliminated in schools at all levels and educate teachers about the harmful effects of discriminatory stereotypes, as well as about alternative ways to teach children about gender equality and non-stereotypical roles of women and |

| | |
|---|---|
| | men;<br><br>(c) Continue to adopt innovative measures, including through the media, social media and activities targeting young people, in collaboration with civil society and community leaders, to strengthen the understanding of gender equality, promote positive masculinity and increase non-stereotypical portrayals of women and men. |
| Gender-based violence against women | 25. Recalling its general recommendation No. 35 (2017) on gender-based violence against women, updating general recommendation No. 19, the Committee recommends that the State party:<br><br>(a) Systematically assess the impact of measures adopted to combat gender-based violence against women and girls, and continue to explore and adopt innovative approaches to address the root causes of such violence;<br><br>(b) Undertake a comprehensive review of the law on the prevention of domestic violence and the protection of victims and amend its provisions to define, prohibit and criminalize all forms of gender-based violence, including domestic violence and marital rape, to facilitate the process of obtaining protection orders and to ensure that victims/survivors of domestic violence have access to effective remedies and that perpetrators are held accountable;<br><br>(c) Increase the availability, accessibility and quality of essential services and support to victims/survivors of gender-based violence, including legal assistance, victim/survivor-centred health-care services and psychosocial support, and continue to explore the possibility of establishing one-stop service centres for victims/survivors of gender-based violence;<br><br>(d) Systematically collect data on gender-based violence against women and girls, disaggregated by age, ethnicity, disability, geographical location and relationship between the victim and the perpetrator. |
| Trafficking and exploitation of prostitution | 27. The Committee recommends that the State party:<br><br>(a) Address the root causes of trafficking in women and girls by promoting income-generating opportunities and improving the economic situation of women, especially in rural areas;<br><br>(b) Ensure early identification of and referral to appropriate services for women and girls who are victims of trafficking, including by providing systematic training to all relevant law enforcement officials on the effective implementation of guidelines on victim identification;<br><br>(c) Ensure the rehabilitation and social integration of victims, including by providing them with effective protection, including shelters, assistance and remedies, and by providing financial and other forms of support to civil society organizations offering assistance to women who are victims of trafficking; |

| | |
|---|---|
| | (d) Ensure that women who are victims of trafficking are exempted from any liability and provided with adequate protection, such as witness protection programmes and temporary residence permits, irrespective of their ability or willingness to cooperate with the prosecutorial authorities;<br>(e) Ensure that traffickers and other actors involved in trafficking are prosecuted and adequately punished;<br>(f) Ensure that measures to combat trafficking, including anti-trafficking legislation, are used for the purposes of prosecuting traffickers and providing effective remedies to victims and that they are not misused against individuals who are not responsible for trafficking offences. |
| | 29. The Committee recommends that the State party:<br>(a) Revise its national legislation to decriminalize women in prostitution;<br>(b) Investigate and punish individuals who exploit women in prostitution;<br>(c) Address the root causes of prostitution, such as poverty and structural gender inequalities, as well as the demand for prostitution, and adopt targeted measures to prevent women in vulnerable situations from being exploited in prostitution, including by providing women who wish to leave prostitution with exit programmes and alternative income opportunities;<br>(d) Provide assistance, rehabilitation and reintegration programmes for women and girls exploited in prostitution. |
| Participation in political and public life | 31. The Committee recommends that the State party:<br>(a) Adopt measures, including temporary special measures, such as quotas, in accordance with article 4 (1) of the Convention and the Committee's general recommendation No. 25 (2004) and general recommendation No. 23 (1997) on women in political and public life, in order to accelerate the full and equal participation of women in political and public life, including in legislative bodies, ministerial posts and local governments, as well as in the judiciary, the police force, the foreign service and academic institutions, particularly at the decision-making level;<br>(b) Create an enabling environment for the participation of women in political and public life, in particular with regard to women belonging to ethnic minority groups, indigenous women and women with disabilities, including by raising awareness among political leaders and the general public that the full, free and democratic participation of women on an equal basis with men in political and public life is a requirement for the full implementation of the rights of women. |

Cambodia/កម្ពុជា

# ឯកសារទស្សនទាន និង របៀបវារៈ

## កិច្ចពិគ្រោះយោបល់លើកទី២ជាមួយសង្គមស៊ីវិល ស្តីពីការតាមដានលើ សេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លើរបាយការណ៍តាមកាលកំណត់លើកទី៣ - យេនឌ័រ

ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣

ទីកន្លែង ៖ (នឹងជម្រាបជូននាពេលក្រោយ)

## I. សាវតា

១. ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២។ យោងតាមមាត្រា ៤0 នៃកតិកាសញ្ញា កម្ពុជា បានដាក់របាយការណ៍ដំបូងរបស់ខ្លួនទៅកាន់ គណៈកម្មាធិការសិទ្ធិមនុស្ស (គណៈកម្មាធិការ) នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៨។ របាយការណ៍នេះត្រូវបានពិនិត្យនៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩។ របាយការណ៍ទីពីរត្រូវបានដាក់ជូននៅខែកញ្ញា ឆ្នាំ២០១២ ហើយការពិនិត្យធ្វើឡើងនៅ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥។ របាយការណ៍ទីបីដែលត្រូវបានដាក់ទៅគណៈកម្មាធិការ នៅថ្ងៃទី២ ខែមេសា ឆ្នាំ២០១៩ ត្រូវបានពិនិត្យដោយគណៈកម្មាធិការក្នុងខែមីនា ឆ្នាំ២០២២ ហើយសេចក្តីសង្កេតសន្និដ្ឋានត្រូវបានចេញនៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២។

២. ក្នុងសេចក្តីសង្កេតសន្និដ្ឋានរបស់ខ្លួន គណៈកម្មាធិការបានអំពាវនាវឱ្យកម្ពុជាផ្សព្វផ្សាយ កតិកាសញ្ញា របាយការណ៍តាមកាលកំណត់ទីបីរបស់ខ្លួន និងសេចក្តីសង្កេតសន្និដ្ឋានបច្ចុប្បន្ន ឱ្យបានទូលំទូលាយ ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញា ក្នុងចំណោមនោះមាន ស្ថាប័នតុលាការ នីតិប្បញ្ញត្តិ និងអាជ្ញាធររដ្ឋបាល សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើសកម្មភាពនៅក្នុងប្រទេស និងសាធារណជនទូទៅ។ ជាជំហានដើម្បីធានាឱ្យមានការផ្សព្វផ្សាយបានទូលំទូលាយ និងតាមដានការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន គណៈ កម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក) សហការជាមួយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស (OHCHR) ប្រចាំនៅកម្ពុជា បានរៀបចំសិក្ខាសាលារួមគ្នាមួយនៅខែវិច្ឆិកា ឆ្នាំ២០២២ ស្តីពីការផ្សព្វផ្សាយ និងផែនការអនុវត្តសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការ។

៣. ដើម្បីធានាឱ្យមានការតាមដានអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន និងសិក្ខាសាលាតាមដានការផ្សព្វផ្សាយ និងសិក្ខាសាលាផ្សព្វផ្សាយកាលពីខែវិច្ឆិកា ឆ្នាំ២០២២ គ.ស.ម.ក បានប្តេជ្ញារៀបចំកិច្ចពិគ្រោះយោបល់ជាបន្តបន្ទាប់ ជាមួយសង្គមស៊ីវិល ស្តីពីការតាមដានការអនុវត្តអនុសាសន៍។

៤. ដោយពិចារណាថាយេនឌ័រ នៅតែជាប្រធានបទដែលបន្តលេចឡើងក្នុងអនុសាសន៍ជាច្រើន[1] ដែលបានផ្តល់មកកម្ពុជាតាមរយៈស្ថាប័នសន្ធិសញ្ញា និងគិតពិចារណាពីភាពចាំបាច់ក្នុងការធានាឱ្យមានសមភាពយេនឌ័រ រួមទាំងតាមរយៈការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) សមភាពយេនឌ័រត្រូវបានផ្តល់អាទិភាព ក្នុងអនុសាសន៍តាមប្រធានបទនៅក្នុងសេចក្តីសង្កេតសន្និដ្ឋានដែលនឹងត្រូវលើកយកមកពិភាក្សាក្នុងសិក្ខាសាលាផ្សព្វផ្សាយ និងអនុវត្តនាពេលខាងមុខ។

## II. គោលបំណង

គោលបំណងនៃសិក្ខាសាលាផ្សព្វផ្សាយ និងអនុវត្តស្តីពីសមភាពយេនឌ័រ មានដូចជា ៖

- ពិភាក្សាអំពីផែនការអនុវត្តរបស់ក្រសួងពាក់ព័ន្ធទាក់ទង នឹងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ជាពិសេសផ្នែកសមភាពយេនឌ័រ ដោយគិតគូរពីអនុសាសន៍មុនៗរបស់គណៈកម្មាធិការ ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ។
- កំណត់តួនាទី និងពិភាក្សាអំពីការទទួលខុសត្រូវរបស់ អង្គការសង្គមស៊ីវិល (CSOs) ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងអ្នកពាក់ព័ន្ធដទៃទៀត ក្នុងការគាំទ្រផែនការអនុវត្តរបស់ ក្រសួងពាក់ព័ន្ធ និង
- ពិភាក្សាអំពីជំហានបន្ទាប់ទាក់ទងនឹងផែនការផ្សព្វផ្សាយ និងការអនុវត្ត រួមទាំងការផ្តល់អាទិភាពលើអនុសាសន៍តាមប្រធានបទដែលត្រូវជជែកពិភាក្សាបន្ត និងធ្វើសកម្មភាពរួមគ្នា រួមទាំងយុទ្ធនាការលើកកម្ពស់ការយល់ដឹងដែលអាចរៀបចំដោយក្រសួង អង្គការសង្គមស៊ីវិល និងស្ថាប័នអង្គការសហប្រជាជាតិ។

## III. អ្នកចូលរួម

- ២០ នាក់មកពីក្រសួងពាក់ព័ន្ធ
- ១៥ នាក់មកពីអង្គការសង្គមស៊ីវិល
- ទីភ្នាក់ងារអង្គការសហប្រជាជាតិ

---

[1] រួមទាំងគណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW) (CEDAW/C/KHM/CO/6) គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (CESCR), (E/C.12/KHM/CO/2, 27 March 2023) និងអនុសាសន៍ទទួលបានពីការត្រួតពិនិត្យឡើងវិញជាសាកលតាមកាលកំណត់ (UPR) (A/HRC/41/17, A/HRC/41/17/Add.1)

# របៀបវារៈ

| ម៉ោង | សកម្មភាព | ទំនួលខុសត្រូវ |
|---|---|---|
| ៧:៣០-៨:៣០ | ការមកដល់របស់អ្នកចូលរួម | |
| ៨:៣០-៨:៣៥ | សេចក្តីផ្តើម និងគោរពភ្លេងជាតិ | |
| ៨:៣៥-៨:៤០ | សុន្ទរកថាស្វាគមន៍ | ➢ សុន្ទរកថាស្វាគមន៍ លោកស្រី **រួអេដា អិល ហាច** តំណាងប្រចាំប្រទេស OHCHR<br>➢ សុន្ទរកថាស្វាគមន៍ លោកស្រី **Camilla Ottosson** ប្រធានការិយាល័យស្ថានទូតស៊ុយអែតប្រចាំភ្នំពេញ (TBC)<br>➢ សុន្ទរកថាស្វាគមន៍ លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី (TBC)<br>➢ សុន្ទរកថាបើកកម្មវិធី ដោយ **ឯកឧត្តម កែវ រ៉េមី** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា(គ.ស.ម.ក) |
| ៨:៤០-៩:០០ | ទិដ្ឋភាពទូទៅនៃសេចក្តីសង្កេតសន្និដ្ឋានទាក់ទងនឹងសមភាពយេនឌ័រ<br>សំណួរ & ចម្លើយ | គ.ស.ម.ក |
| ៩:០០-១០:០០ | ផែនការអនុវត្តរបស់ក្រសួង | ➢ ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី (TBC)<br>➢ ក្រសួងយុត្តិធម៌ (TBC)<br>➢ ក្រសួងមហាផ្ទៃ (TBC) |

| | | |
|---|---|---|
| | | ➢ ក្រសួងព័ត៌មាន (TBC) |
| ១០:០០-១០:១៥ | សម្រាកអាហារសម្រន់ | |
| ១០:១៥-១១:១៥ | ការរួមចំណែករបស់សង្គមស៊ីវិលក្នុងការអនុវត្តសេចក្តីសង្កេតសន្និដ្ឋាន | ➢ អង្គការសីលកា (TBC)<br>➢ អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC) (TBC)<br>➢ អង្គការ NGO-CEDAW (TBC) |
| ១១:១៥-១២:០០ | ការពិភាក្សាជាក្រុម | ទាំងអស់គ្នា |
| ១២:០០-១២:១០ | សុន្ទរកថាបិទកម្មវិធី | គ.ស.ម.ក |
| ១២:១០ | អាហារថ្ងៃត្រង់រួមគ្នា | |

## IV. ឧបសម្ព័ន្ធ (អនុសាសន៍ដោយគណៈកម្មាធិការ និងអនុសាសន៍នានាពាក់ព័ន្ធនឹងយេនឌ័រ ដែលផ្តល់ដោយយន្តការសិទ្ធិមនុស្សអន្តរជាតិ)

*សេចក្តីសង្កេតសន្និដ្ឋានទៅលើរបាយការណ៍តាមកាលកំណត់លើកទី ៣ សម្រាប់កម្ពុជា ដែលទទួលបានពីគណៈកម្មាធិការសិទ្ធិមនុស្ស (CCPR/C/KHM/CO/3, ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២)*

| ប្រធានបទ | អនុសាសន៍ | កថាខណ្ឌ |
|---|---|---|
| សមភាព យេនឌ័រ | ធានាថាច្បាប់និងគោលនយោបាយទាំងឡាយស្តីពីសមភាពយេនឌ័រ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងពិនិត្យឡើងវិញលើច្បាប់ការងារ ឆ្នាំ១៩៩៧ ក្នុងគោលបំណងធានាការអនុវត្តគោលការណ៍ស្តីពីការទទួលបានប្រាក់ខែស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នា ព្រមទាំងការធានានូវការការពារពេញលេញដល់អ្នកធ្វើការងារតាមផ្ទះ។ | កថាខណ្ឌ១៧ (ក) |
| | លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគោលការណ៍សមភាពរវាងស្ត្រី និងបុរស និងតម្រូវការក្នុងការលុបបំបាត់ផ្នត់គំនិតផ្នែកយេនឌ័រ ព្រមទាំងធានាថាប្រព័ន្ធផ្សព្វផ្សាយនានា លើកកម្ពស់រូបភាពវិជ្ជមានរបស់ស្ត្រី ក្នុងនាមជាអ្នកចូលរួមដ៏សកម្មក្នុងជីវិតសាធារណៈ និងនយោបាយ។ | កថាខណ្ឌ១៧ (ខ) |
| | បង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឱ្យសម្រេចឱ្យបាននូវការចូលរួមពេញលេញ និងស្មើភាពរបស់ស្ត្រីក្នុងជីវិតនយោបាយ និងសាធារណៈ ក្នុងរយៈពេលកំណត់ជាក់លាក់ រួមមានក្នុងរដ្ឋសភា តួនាទីតាមក្រសួង រាជធានី/ក្រុងតាមតំបន់ និងមូលដ្ឋាន និងតុលាការ ជាពិសេស ក្នុងតួនាទីធ្វើសេចក្តីសម្រេចចិត្ត។ | កថាខណ្ឌ១៧ (គ) |
| អំពើហិង្សាប្រឆាំងនឹងនារីភេទ | ដោយរំឭកឡើងវិញពីអនុសាសន៍របស់គណៈកម្មាធិការនាពេលកន្លងមក ស្តីពីអំពើហិង្សាផ្អែកលើយេនឌ័រ រដ្ឋភាគីគួរតែចាត់វិធានការផ្សេងៗដើម្បីធានាថា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីផ្តល់និយមន័យ និងដាក់ទោសឱ្យបានគ្រប់ជ្រុងជ្រោយលើអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងធានាការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព អនុលោមតាមកតិកាសញ្ញានេះ និងបទដ្ឋានអន្តរជាតិដទៃទៀត។ | កថាខណ្ឌ១៩ |
| | រដ្ឋភាគីគួរតែធានាផងដែរថា រាល់ករណីអំពើហិង្សាប្រឆាំងនឹងនារីភេទ ត្រូវបានស៊ើបអង្កេតយ៉ាងហ្មត់ចត់ ជនល្មើសត្រូវបានកាត់ទោស និងប្រសិនបើមានទោសត្រូវដាក់ឱ្យសមាមាត្រ និងថាជនរងគ្រោះត្រូវទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ទទួលបានការជួសជុលពេញលេញ រួមទាំងសំណងគ្រប់គ្រាន់ | កថាខណ្ឌ១៩ |

| | | |
|---|---|---|
| | ព្រមទាំងទទួលបានការការពារ និងជំនួយគ្រប់គ្រាន់។ | |
| | រដ្ឋភាគីគួរតែបន្តធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង ស្តីពីអំពើហិង្សាប្រឆាំងនឹងនារីភេទដល់សាធារណជន និងធានាថាអ្នកមានមុខងារផ្សេងៗនៅក្នុងប្រព័ន្ធច្បាប់ រួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ ទទួលបានការបណ្តុះបណ្តាលពាក់ព័ន្ធនឹងបញ្ហានេះ។ | កថាខណ្ឌ១៩ |

*<u>អនុសាសន៍ ដែលបានមកពីការត្រួតពិនិត្យឡើងវិញជាសកលតាមកាលកំណត់ (UPR) ស្តីពីយេនឌ័រ (A/HRC/41/17, A/HRC/41/17/Add.1)</u>*

| | |
|---|---|
| **ច្បាប់ និងគោលនយោបាយដើម្បីលុបបំបាត់ការរើសអើងដោយផ្អែកលើយេនឌ័រ** | ១១០.៤៩ ពង្រឹងគោលនយោបាលដីធ្លី ដែលបានអនុម័តកាលពីឆ្នាំ ២០១៥ ដែលចែងថាសមភាព និងសមធម៌យេនឌ័ររវាងបុរស និងស្ត្រី គួរត្រូវបានធានានៅក្នុងដំណើរការនៃការចុះបញ្ជីដីធ្លី។ (រដ្ឋពហុជាតិនៃបូលីវី)<br><br>១១០.៥០ ដោយពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល អនុម័តច្បាប់ និងគោលនយោបាយដែលគ្រប់ជ្រុងជ្រោយប្រឆាំងនឹងការរើសអើង និងអំពើហិង្សាដោយសារទំនោរផ្លូវភេទ ឬអត្តសញ្ញាណយេនឌ័រ និងធានាការអនុវត្តច្បាប់ និងគោលនយោបាយទាំងនេះ នៅក្នុងស្ថាប័នសាធារណៈទាំងអស់ ជាពិសេសក្នុង វិស័យអប់រំសុខាភិបាល និងការងារ។ (ម៉ិចស៊ិកូ)<br><br>១១០.១៧២ លុបចោលការហាមប្រាមដែលមានលក្ខណៈរើសអើងចំពោះស្ត្រីដែលចង់រៀបការម្តងទៀតក្នុងរយៈពេល១២០ថ្ងៃ បន្ទាប់ពីការលែងលះ ឬទុកជាមោឃៈ។ (អ៊ីស្លង់)<br><br>១១០.១៨៥ ធ្វើកំណែទម្រង់ច្បាប់ជាតិ ដើម្បីពង្រឹងកិច្ចការពារដល់ស្ត្រី និងកុមារ ពីអំពើហិង្សាក្នុងគ្រួសារ។ (សហព័ន្ធរុស្ស៊ី); |
| **វិធានការលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ** | ១១០.១៣២ ជម្នះឧបសគ្គនានា ដើម្បីទទួលបានយុត្តិធម៌សម្រាប់ស្ត្រីរងគ្រោះពីអំពើហិង្សា។ (អ៊ីរ៉ាក់)<br><br>១១០.១៧៩ ធានានូវកិច្ចខិតខំប្រឹងប្រែង ដើម្បីលុបបំបាត់រាល់ទម្រង់នៃអំពើហិង្សា និងការរើសអើងដោយហេតុផលយេនឌ័រ ព្រមទាំងធានានូវការផ្តល់អំណាចដល់ក្រុមងាយរងគ្រោះទាំងអស់។ (នេប៉ាល់) |

| | |
|---|---|
| | ១១០.១៨០ ពង្រឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីការពារសិទ្ធិរបស់ក្រុមងាយរងគ្រោះបំផុត ដូចជាស្ត្រី កុមារ និងជនពិការ ព្រមទាំងដើម្បីបង្ការ និងប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ និងការកេងប្រវ័ញ្ចផ្លូវភេទ ក៏ដូចជាទម្រង់ដទៃទៀតនៃអំពើហិង្សា រួមទាំងអំពើហិង្សាក្នុងគ្រួសារ។(អ៊ីតាលី) ;<br><br>១១០.១៨២ ផ្តល់វគ្គបណ្តុះបណ្តាលជាកាតព្វកិច្ចស្តីពីនីតិវិធីផ្តន្ទាទោសលើករណីនៃអំពើហិង្សាលើយេនឌ័រ ដល់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ។ (សាធារណរដ្ឋម៉ុលដូវ៉ា);<br><br>១១០.១៨៣ បែងចែកធនធានមនុស្ស និងហិរញ្ញវត្ថុឱ្យបានគ្រប់គ្រាន់ដើម្បីបង្កើតមជ្ឈមណ្ឌល សេវាកម្មច្រកចេញចូលតែមួយ ឱ្យបានយ៉ាងតិច៥មណ្ឌល នៅត្រឹមឆ្នាំ២០២៤ ដើម្បីផ្តល់សេវា គាំទ្រដោយមិនគិតថ្លៃដល់ជនរងគ្រោះនៃអំពើហិង្សាផ្អែកលើយេនឌ័រ។ (អូស្ត្រាលី)<br><br>១១០.១៨៤ ធ្វើការស៊ើបអង្កេតឱ្យបានគ្រប់ជ្រុងជ្រោយអំពីករណីនៃអំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ ព្រមទាំងធានាថា ជនល្មើសត្រូវបានផ្តន្ទាទោស ហើយជនរងគ្រោះត្រូវទទួលបានសំណងសមរម្យ។ (សាធារណរដ្ឋម៉ុលដូវ៉ា) |
| **ការពង្រឹងសិទ្ធិស្ត្រី និងលើកកម្ពស់ការយល់ដឹង** | ១១០.១៧៣ បន្តយន្តការកំពុងអនុវត្ត សម្រាប់សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី។ (ឥណ្ឌា)<br><br>១១០.១៧៤ បន្តអនុវត្តគោលនយោបាយសមភាពយេនឌ័រ ដើម្បីធានាការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យ និងកម្មវិធីទាំងអស់។ (ប៉ាគីស្ថាន)<br><br>១១០.១៧៥ ពង្រឹងបន្ថែមទៀតនូវកម្មវិធីដោះស្រាយការរើសអើងប្រឆាំងស្ត្រី និងក្មេងស្រី និងលើកកម្ពស់សមភាពយេនឌ័រ។ (ហ្វីលីពីន)<br><br>១១០.១៧៦ បន្តអនុវត្តគោលនយោបាយសមភាពយេនឌ័រ តាមរយៈការបញ្ជ្រាបយេនឌ័រទៅក្នុងវិស័យ និងកម្មវិធីទាំងអស់។ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ)<br><br>១១០.១៧៧ បង្កើនកិច្ចខិតខំប្រឹងប្រែងទ្វេដង ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីក្នុងវិស័យច្បាប់ និងបញ្ចប់ការអនុវត្តន៍ដ៏គ្រោះថ្នាក់ និងផ្នត់គំនិតមានលក្ខណៈរើសអើងដែលធ្វើឱ្យស្ត្រីកម្ពុជា ក្លាយជា |

| | |
|---|---|
| | ជនរងគ្រោះ។ (អ៊ុយរូហ្គាយ);<br><br>១១០.១៧៨ បន្តអនុវត្តវិធានការនានា សំដៅដល់ការលើកកម្ពស់សិទ្ធិស្ត្រី រួមទាំងការលុបបំបាត់រាល់ទម្រង់ការរើសអើង និងអំពើហិង្សាប្រឆាំងស្ត្រី។ (ម៉ាល់ឌីវ)<br><br>១១០.១៨១ ពង្រឹងតួនាទី និងឋានៈរបស់ស្ត្រី ព្រមទាំងលើកកម្ពស់ និងការពារសិទ្ធិកុមារ និងជនពិការក្នុងសង្គម។ (សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ) |

*<u>សេចក្តីសង្កេតសន្និដ្ឋាន ទៅលើរបាយការណ៍តាមកាលកំណត់លើកទី៦ សម្រាប់ប្រទេសកម្ពុជា របស់គណៈកម្មាធិការស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្ត្រីភេទ (CEDAW/C/KHM/CO/6, ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៩)</u>*

| ប្រធានបទ | អនុសាសន៍ |
|---|---|
| ក្របខ័ណ្ឌច្បាប់ | ៩. គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ដល់រដ្ឋភាគី ៖<br>(ក) ធានាថាលិខិតបទដ្ឋានគតិយុត្តិជាតិ បានដាក់បញ្ចូលនិយមន័យនៃការរើសអើងលើស្ត្រី ដោយគ្របដណ្តប់ការរើសអើងដោយផ្ទាល់ និងដោយប្រយោលនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន រួមទាំងទម្រង់នៃការរើសអើងដែលមានការប្រទាក់ប្រឡាគ្នា ស្របតាមមាត្រា១ នៃអនុសញ្ញានេះ ដូចដែលរដ្ឋភាគីបានទទួលយក បន្ទាប់ពីការពិនិត្យឡើងវិញតាមកាលកំណត់ជាសាកលលើកទីបី (A/HRC/41/17/Add.1, para.2);<br><br>(ខ) ធ្វើការវាយតម្លៃប៉ាន់ប្រមាណផលប៉ះពាល់ យេនឌ័រជាលក្ខណៈប្រព័ន្ធ នៅពេលអនុម័តឬធ្វើវិសោធនកម្មច្បាប់នានា និងធានាថា ការធ្វើវិសោធនកម្មច្បាប់ទាំងនោះ នឹងជួយលើកកម្ពស់និងការពារសិទ្ធិស្ត្រី។ |
| សិទ្ធិទទួលបានយុត្តិធម៌ និងដំណោះស្រាយ | ១១. រំលឹកដល់អនុសាសន៍ទូទៅលេខ ៣៣ (២០១៥) ស្តីពីការទទួលបានយុត្តិធម៌សម្រាប់ស្ត្រី គណៈកម្មាធិការ សូមផ្តល់អនុសាសន៍ថា រដ្ឋភាគីគួរ ៖<br><br>(ក) រៀបចំបង្កើតគម្រោងជំនួយផ្នែកច្បាប់ទូលំទូលាយមួយ ដែលមានការផ្តល់មូលនិធិប្រកបដោយចីរភាព រយៈពេលវែងពីថវិកាជាតិ និងបង្កើតតុលាការឧទ្ធរណ៍ថ្នាក់តំបន់ ក្រៅពីនៅរាជធានី ដើម្បីធានាការទៅកាន់ និងទទួលបាននូវដំណើរការកាត់ក្តីពីតុលាការ និងសាលាជម្រះក្តីប្រកបដោយប្រសិទ្ធភាព ចំពោះស្ត្រីទាំងអស់ ជាពិសេស ស្ត្រីនៅតាមជនបទ ស្ត្រីជនជាតិដើមភាគតិច ស្ត្រីក្នុងក្រុមជាតិពិន្ទុភាគតិច និងស្ត្រីមានពិការភាព។<br><br>(ខ) លុបបំបាត់វប្បធម៌ប្រមាថមាក់ងាយទៅលើស្ត្រីនិងក្មេងស្រី ដែលបានដាក់ពាក្យបណ្តឹងពីការរំលោភបំពានផ្សេងៗទៅលើសិទ្ធិរបស់ពួកគេ តាមរយៈការលើកកម្ពស់ការយល់ដឹងដល់សាធារ |

| | |
|---|---|
| | ណៈជនទូទៅ ស្តីពីសិទ្ធិស្ត្រី។<br><br>(គ) ផ្សព្វផ្សាយព័ត៌មាន ស្តីពីយន្តការ និងនីតិវិធីក្នុងការស្វែងរកដំណោះស្រាយចំពោះការរំលោភបំពានទៅលើសិទ្ធិស្ត្រី និងក្មេងស្រី ជាពិសេសនៅតាមតំបន់ជនបទ។<br><br>(ឃ) ពង្រឹងការឆ្លើយតបតម្រូវការយេនឌ័រ និងការយល់ដឹងជ្រួតជ្រាបអំពីយេនឌ័រ នៃប្រព័ន្ធយុត្តិធម៌ ដោយរួមបញ្ចូលទាំង ការធ្វើឡើងតាមរយៈការបង្កើនចំនួនស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌ និងផ្តល់វគ្គកសាងសមត្ថភាពដែលមានលក្ខណៈជាប្រព័ន្ធ ទៅដល់ចៅក្រម ព្រះរាជអាជ្ញា នគរបាល និងមន្ត្រីអនុវត្តច្បាប់ផ្សេងទៀត ស្តីពីអនុសញ្ញានេះ ក៏ដូចជាសេចក្តីសង្កេតសន្និដ្ឋានរបស់គណៈកម្មាធិការយុត្តាធិការក្រោមពិធីសារបន្ថែម ព្រមទាំងអនុសាសន៍ទូទៅរបស់អនុសញ្ញានេះ។<br><br>(ង) ចាត់វិធានការជាក់លាក់ ដើម្បីពង្រឹងឯករាជ្យភាព និងភាពមិនលម្អៀងនៃប្រព័ន្ធយុត្តិធម៌ និងធានាថា ករណីរើសអើងផ្អែកលើយេនឌ័រ និងអំពើហិង្សាលើស្ត្រី រួមទាំង អំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ ត្រូវបានស៊ើបអង្កេតពេញលេញ ដោយជនល្មើសត្រូវបានកាត់ទោស និងទទួលទណ្ឌកម្ម ហើយជនរងគ្រោះទទួលបានដំណោះស្រាយគ្រប់គ្រាន់។<br><br>(ច) ពង្រឹងវិធានការនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដោយរួមបញ្ចូលទាំង តាមរយៈការអនុម័ត និងការអនុវត្តវិធានការវិន័យដែលមានប្រសិទ្ធភាព ដើម្បីធ្វើឲ្យមន្ត្រីរដ្ឋា ភិបាលមានគណនេយ្យភាព ចំពោះអំពើពុករលួយ ក្នុងគោលបំណងដើម្បីស្តារឡើងវិញនូវទំនុកចិត្តរបស់ស្ត្រីនៅក្នុងប្រព័ន្ធយុត្តិធម៌។ |
41. **The State party should intensify its efforts to ensure the effective implementation of the Law on Juvenile Justice and that children in conflict with the law are treated in a manner commensurate with their age. The State party should also ensure that pretrial detention of minors is strictly used in exceptional cases and only as a last resort. The State party should consider undertaking a thorough review of cases of children in conflict with the law who will be transferred to the new Youth Rehabilitation Centre in order to evaluate an alternative to detention.**

### Indigenous peoples

42. The Committee welcomes the efforts of the State party to enhance protection mechanisms for the rights of indigenous persons. However, the Committee remains concerned about shortcomings in the implementation of the legal framework and safeguards in place for the protection of the right of indigenous peoples to use and occupy their land and territories. It is concerned that indigenous peoples’ right to free, prior and informed consent in decision-making processes affecting them, and particularly in granting approval of development projects on their lands, is not systematically respected. The Committee also expresses its concern about the effective protection of indigenous communities in the context of the COVID-19 pandemic (arts. 2 and 26–27).

43. **The State party should:**

(a) **Develop and adopt a legal framework to recognize and protect the rights of indigenous peoples, including a simplified procedure for obtaining communal land titles;**

(b) **Ensure full and meaningful consultation with indigenous peoples in matters concerning their rights, in particular their right to free, prior and informed consent, including when granting permission for development projects that may affect their land rights;**

(c) **Continue its efforts to prevent conflicts over land use, including by providing guarantees in relation to land traditionally owned or occupied by indigenous peoples;**

(d) **Ensure that indigenous peoples are not relocated without following all legal and procedural safeguards, including the provision of comparable alternatives and adequate compensation;**

(e) **Ensure that in the context of the COVID-19 pandemic indigenous peoples have access to information and health-care services, including testing, treatment and vaccines.**

## D. Dissemination and follow-up

44. **The State party should widely disseminate the Covenant, its third periodic report and the present concluding observations with a view to raising awareness of the rights enshrined in the Covenant among the judicial, legislative and administrative authorities, civil society and non-governmental organizations operating in the country, and the general public. The State party should ensure that the periodic report and the present concluding observations are translated into the official languages of the State party.**

45. **In accordance with rule 75 (1) of the Committee's rules of procedure, the State party is requested to provide, by 25 March 2025, information on the implementation of the recommendations made by the Committee in paragraphs 9 (corruption), 35 (freedom of expression) and 39 (political participation) above.**

46. **In line with the Committee's predictable review cycle, the State party will receive in 2028 the Committee's list of issues prior to the submission of the report and will be expected to submit within one year its replies to the list of issues, which will constitute its fourth periodic report. The Committee also requests the State party, in preparing the report, to broadly consult civil society and non-governmental organizations operating in the country. In accordance with General Assembly resolution 68/268, the word limit for the report is 21,200 words. The next constructive dialogue with the State party will take place in 2030 in Geneva.**

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

ចែកចាយ ៖ ទូទៅ
១៨ ឧសភា ២០២២

ភាសាដើម ៖ អង់គ្លេស

**គណៈកម្មាធិការសិទ្ធិមនុស្ស**

## សេចក្តីសង្កេតសន្និដ្ឋាននៅលើរបាយការណ៍តាមកាលកំណត់លើកទី៣របស់កម្ពុជា

១. គណៈកម្មាធិការបានធ្វើការពិនិត្យទៅលើរបាយការណ៍តាមកាលកំណត់លើកទី៣របស់កម្ពុជា[1] នៅកិច្ចប្រជុំលើកទី៣៨៥០ លើកទី៣៨៥២ និងលើកទី៣៨៥៤[2] របស់ខ្លួន ដែលបានធ្វើឡើងនៅថ្ងៃទី៩ ទី១០ និងទី ១១ ខែមីនា ឆ្នាំ២០២២។ កិច្ចប្រជុំបានធ្វើឡើងក្នុងទម្រង់បត់បែន ដោយសារការរាតត្បាតនៃមេរោគកូរ៉ូណា (កូវីដ១៩)។ នៅក្នុងកិច្ចប្រជុំលើកទី៣៨៦៨ និង៣៨៧០ ដែលបានធ្វើឡើងនៅថ្ងៃទី២២ និង២៣ ខែមីនា ឆ្នាំ២០២២ គណៈកម្មាធិការបានអនុម័តយកនូវសេចក្តីសង្កេតសន្និដ្ឋាន។

## ក. សេចក្តីផ្តើម

២. គណៈកម្មាធិការបានធ្វើការស្វាគមន៍ ចំពោះការដាក់ជូនរបាយការណ៍ដំណាក់កាលទីបីរបស់ព្រះរាជាណាចក្រកម្ពុជា និងព័ត៌មានដែលបានបង្ហាញជូននៅក្នុងរបាយការណ៍នេះ។ គណៈកម្មាធិការ បានបង្ហាញនូវការកោតសរសើរ ចំពោះឱកាសចូលរួមកិច្ចសន្ទនាក្នុងន័យស្ថាបនាជាមួយគណៈប្រតិភូជាន់ខ្ពស់នៃរដ្ឋភាគី ទៅលើវិធានការដែលបានធ្វើឡើងនៅអំឡុងពេលដែលរបាយការណ៍នេះត្រូវបានធ្វើឡើង ដើម្បីអនុវត្តបទប្បញ្ញត្តិនៃកតិកាសញ្ញា។ គណៈកម្មាធិការ ពិតជាអរគុណចំពោះរដ្ឋភាគី ចំពោះការឆ្លើយតបជាលាយលក្ខណ៍អក្សរ[3] ទៅលើបញ្ជីបញ្ហាដែលបានលើកឡើង[4] ដែលនេះជាឯកសារជំនួយបន្ថែមពីលើការឆ្លើយតបជាពាក្យសម្តីពីសំណាក់គណៈប្រតិភូ និងចំពោះការផ្តល់ព័ត៌មានបន្ថែមជាលាយលក្ខណ៍អក្សរ។

## ខ. វិជ្ជមានភាពវិជ្ជមាន

៣. គណៈកម្មាធិការស្វាគមន៍ចំពោះរដ្ឋភាគីក្នុងការទទួលយកមកអនុវត្តនូវវិធានការច្បាប់ គោលនយោបាយ និងស្ថាប័ន ដូចខាងក្រោមនេះ ៖

(ក) ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ និងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការអនុវត្តយុត្តិធម៌អនីតិជន ឆ្នាំ២០១៨-២០២០

[1] CCPR/C/KHM/3
[2] CCPR/C/SR.3850, CCPR/C/SR.3852 និង CCPR/C/SR.3854
[3] CCPR/C/KHM/RQ/3
[4] CCPR/C/KHM/Q/3

(ខ) អនុក្រឹត្យលេខ១៥៥ ស្តីអំពីការរៀបចំ និងដំណើរការមជ្ឈមណ្ឌលយុវស្តារនីតិសម្បទា ចុះថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០១៧ សម្រាប់ការគ្រប់គ្រងអនីតិជន

(គ) ផែនការសកម្មភាពជាតិលើកទី៣ ស្តីអំពីការទប់ស្កាត់អំពើហិង្សាទៅលើស្ត្រី ឆ្នាំ២០១៩-២០២៣

(ឃ) ការបង្កើតឱ្យមានគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងការប្រព្រឹត្តមកលើខ្លួន ឬទណ្ឌកម្មឯទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ទាបបន្ថោក ដោយយោងតាមព្រះរាជក្រឹត្យលេខ ០៨១៧/៦១៩ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៧

(ង) ផែនការយុទ្ធសាស្ត្រជាតិស្តីពីការកំណត់អត្តសញ្ញាណ ឆ្នាំ២០១៧-២០២៦ ដើម្បីធានាថាប្រជាពលរដ្ឋគ្រប់រូបទទួលបាននូវអត្តសញ្ញាណស្របច្បាប់

## គ. បញ្ហាចម្បងនៃការព្រួយបារម្ភ និងអនុសាសន៍

### លទ្ធភាពសមស្របក្នុងការអនុវត្តកតិកាសញ្ញា

៤. ខណៈពេលដែលមានការកត់សម្គាល់ថារដ្ឋភាគី បានរៀបចំវគ្គបណ្តុះបណ្តាលជាបន្តបន្ទាប់ ស្តីអំពីសិទ្ធិមនុស្សជាសកល រួមបញ្ចូលទាំងកតិកាសញ្ញានេះ ទៅកាន់អង្គចៅក្រម និងមេធាវី គណៈកម្មាធិកានៅតែបន្តមានការព្រួយបារម្ភ អំពីកង្វះការអនុវត្តជាក់ស្តែងទាក់ទងនឹងសិទ្ធិទាំងឡាយដែលបានចែងក្នុងកតិកាសញ្ញានេះពីសំណាក់តុលាការ ក្នុងសេចក្តីសម្រេចរបស់ខ្លួន និងការកើតឡើងនូវចន្លោះប្រហោងនៃការការពារ។ គណៈកម្មាធិកាពិតជាសោកស្តាយដែលរដ្ឋភាគីមិនទាន់បានផ្តល់សច្ចាប័នទៅលើ ពិធីសារបន្ថែមទីមួយ (the first Optional Protocol ) លើកតិកាសញ្ញាដែលអាចផ្តល់ឱកាសសម្រាប់ ការបញ្ជូនទំនាក់ទំនងជាលក្ខណៈបុគ្គល (មាត្រា២)។

**៥. រដ្ឋភាគីគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនបន្ថែមទៀត ក្នុងការបង្កើនការយល់ដឹងស្តីអំពីកតិកាសញ្ញា របស់អង្គចៅក្រម ព្រះរាជអជ្ញា មេធាវី និងសាធារណៈជន ឱ្យបានទូលំទូលាយ ដើម្បីធានាឱ្យបាននូវការអនុវត្តកតិកាសញ្ញានេះ នៅក្នុងតុលាការជាតិ។ រដ្ឋភាគីគួរតែផ្តល់សច្ចាប័នទៅលើពិធីសារបន្ថែមទីមួយ (the first Optional Protocol) លើកតិកាសញ្ញា ដែលអាចផ្តល់ឱកាសសម្រាប់ ការបញ្ជូនទំនាក់ទំនងជាលក្ខណៈបុគ្គល។**

### ស្ថាប័នសិទ្ធិមនុស្សជាតិ

៦. គណៈកម្មាធិការបានកត់សម្គាល់ឃើញ នូវដំណើរការនៃការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិរបស់រដ្ឋភាគី តាមរយៈការរៀបចំសេចក្តីព្រាងច្បាប់ថ្មីនៅឆ្នាំ២០២១។ ក៏ប៉ុន្តែ គណៈកម្មាធិការនៅតែមានសេចក្តីព្រួយបារម្ភ អំពីកង្វះសេចក្តីទុកចិត្ត ដែលបានលើកឡើងដោយសង្គមស៊ីវិល អ្នកការពារសិទ្ធិមនុស្ស និងសហជីពចំពោះការបង្កើតនូវស្ថាប័នសិទ្ធិមនុស្សជាតិ ដែលគួរឱ្យជឿជាក់ មានប្រសិទ្ធភាព និងឯករាជ្យ ដោយការខ្វះខាតនូវដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ (មាត្រា២)។

៧. រំលឹកឡើងវិញនូវអនុសាសន៍លើកមុនរបស់គណៈកម្មាធិការ[5] រដ្ឋភាគីគួរតែជំរុញដំណើរការឈានទៅមុខមួយកម្រិតទៀត ក្នុងការបង្កើតស្ថាប័នសិទ្ធិមនុស្សជាតិ ដោយផ្អែកលើគោលការណ៍ស្តីពីឋានៈនៃស្ថាប័នជាតិដើម្បីសិទ្ធិមនុស្ស សម្រាប់ការលើកកម្ពស់ និងការការពារសិទ្ធិមនុស្ស (គោលការណ៍ទីក្រុងប៉ារីស)។ រដ្ឋភាគីគួរតែរៀបចំដំណើរការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ ប្រកបដោយភាពបើកចំហ តម្លាភាព និងមានអត្ថន័យជាមួយភាគីពាក់ព័ន្ធនានា រួមទាំងសង្គមស៊ីវិលដែរ។

វិធានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

៨. បើទោះបីជាមានការអនុវត្តវិធានការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយក្តី ក៏គណៈកម្មាធិការនៅតែមានការព្រួយបារម្ភពីកង្វះខាតនីតិវិធីការពារក្នុងច្បាប់ស្តីអំពីការប្រឆាំងអំពើពុករលួយ ក៏ដូចជាការខ្វះខាតការអនុវត្តច្បាប់ដែលមានប្រសិទ្ធិភាព។ គណៈកម្មាធិការនៅតែបន្តព្រួយបារម្ភពីកង្វះខាតនៃឯករាជ្យភាព និងការស៊ើបអង្កេតដោយមានប្រសិទ្ធិភាព របស់អង្គភាពប្រឆាំងអំពើពុករលួយ និងទិន្នន័យរាយការណ៍ពីអំពើពុករលួយនៅមានកម្រិតទាប ឬតិចតួច ដែលជនល្មើសទទួលរងការពិន័យ ដែលក្នុងនោះភាពភ័យខ្លាចពីការសងសឹកជាមូលហេតុមួយផងដែរ។ គណៈកម្មាធិការក៏បានកត់សម្គាល់ដោយការព្រួយបារម្ភ ពីការរាយការណ៍អំពីអំពើពុករលួយទាក់ទងនឹងការចាប់យកដីធ្លី និងការឈ្លានពានកាប់បំផ្លាញតំបន់ព្រៃការពារ ក៏ដូចជាការកាប់ព្រៃឈើខុសច្បាប់ និងភាពមិនប្រក្រតីក្នុងការផ្តល់សម្បទានសម្រាប់គម្រោងអភិវឌ្ឍន៍។

៩. រដ្ឋភាគីគួរបន្ថែមកិច្ចខំប្រឹងប្រែងរបស់ខ្លួនក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើពុករលួយ និងនិទណ្ឌភាពគ្រប់កម្រិត។ រដ្ឋភាគីគួរតែធានាថា គ្រប់ករណីនៃអំពើពុករលួយទាំងអស់ រួមទាំងករណីទាំងឡាយណាដែលទាក់ទងនឹងបញ្ហាដីធ្លី ការកាប់ព្រៃឈើខុសច្បាប់ និងកិច្ចសន្យាសម្រាប់គម្រោងអភិវឌ្ឍន៍ ត្រូវបានស៊ើបអង្កេតប្រកបដោយឯករាជ្យភាព និងច្បាស់លាស់ត្រឹមត្រូវ ព្រមទាំងដាក់ទោសចំពោះបុគ្គលទាំងឡាយដែលមានទំនួលខុសត្រូវលើបញ្ហានេះ ហើយជនរងគ្រោះត្រូវបានផ្តល់សំណងពេញលេញ។ រដ្ឋភាគីគួរធានាឱ្យបាននូវការការពារគ្រប់គ្រាន់សម្រាប់បុគ្គលរាយការណ៍ សាក្សី និងជនរងគ្រោះពីអំពើពុករលួយ រួមបញ្ចូលទាំងការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីការបុគ្គលរាយការណ៍ និងសេចក្តីព្រាងច្បាប់ស្តីពីសាក្សី អ្នកជំនាញការ និងជនរងគ្រោះ ក្រោយពីបានរៀបចំកិច្ចពិគ្រោះយោបល់ ប្រកបដោយភាពបើកចំហ តម្លាភាព និងមានអត្ថន័យ ជាមួយសង្គមស៊ីវិល និងភាគីពាក់ព័ន្ធផ្សេងទៀត។

ការគ្រប់គ្រងប្រទេសក្នុងភាពអាសន្ន

១០. គណៈកម្មាធិការមានការព្រួយបារម្ភអំពីព័ត៌មានដែលទទួលបានអំពីអំណាច ដ៏មានឥទ្ធិពលរបស់ច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលបានប្រកាសឱ្យប្រើ នៅខែមេសា ឆ្នាំ២០២០ បានផ្តល់សិទ្ធិយ៉ាងខ្លាំងឱ្យរដ្ឋាភិបាលក្នុងការរឹតត្បិតសិទ្ធិសេរីភាពជាមូលដ្ឋានជាច្រើន។ នេះពិតជាបង្កឱ្យមានការព្រួយ

---

[5] CCPR/C/KHM/CO/2, កថាខណ្ឌទី៦.

បារម្ភជាខ្លាំងអំពីការប្រើប្រាស់ និងអនុវត្តច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ដែលបានប្រកាសឱ្យប្រើនៅខែមីនា ឆ្នាំ២០២១ ដែលបានកំណត់ទណ្ឌកម្មធ្ងន់ធ្ងរ ចំពោះករណីដែលមិនអនុលោមតាម ឈានទៅរកការរឹតត្បឹតដោយមិនសមស្របលើសិទ្ធិសេរីភាពជាមូលដ្ឋាន ជាពិសេសនៅពេលដែលច្បាប់នេះត្រូវបានប្រើដើម្បីបំបែកការជួបប្រជុំដោយសន្តិវិធី។ គណៈកម្មាធិការសោកស្តាយចំពោះកង្វះខាតនៃការជជែកដេញដោល និងពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិល មុនការប្រកាសឱ្យប្រើច្បាប់ទាំងនេះ (មាត្រា៤)។

១១. រដ្ឋភាគីគួរពិនិត្យឡើងវិញ និងធ្វើវិសោធនកម្មច្បាប់ ស្តីអំពីស្ថានភាពអាសន្ន និងជំងឺកូវីដ-១៩ ដើម្បីធានាឱ្យបាននូវអនុលោមភាពរបស់ខ្លួននឹងតម្រូវការរបស់មាត្រាទី៤ នៃកតិកាសញ្ញានេះ ដូចបានបកស្រាយនៅក្នុងសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការលេខ ២៩ (ឆ្នាំ២០០១) ស្តីពីការចាកឆ្ងាយពីបទប្បញ្ញត្តិរបស់កតិកាសញ្ញាអំឡុងពេលស្ថានភាពអាសន្ន និងសេចក្តីថ្លែងការណ៍របស់គណៈកម្មាធិការស្តីពីការចាកឆ្ងាយពីបទប្បញ្ញត្តិដែលទាក់ទងនឹងការរាតត្បាតនៃជំងឺកូវីដ១៩[6]។ រដ្ឋភាគីគួរធានាឱ្យបានថា រាល់យន្តការទាំងអស់ដែលបានដាក់ឱ្យអនុវត្តដើម្បីការពារប្រជាជនក្នុងស្ថានភាពអាសន្ន រួមទាំងការរីករាលដាលនៃជំងឺឆ្លង ជាវិធានការបណ្តោះអាសន្ន សមាមាត្រ និងមានភាពចាំបាច់ពិតប្រាកដ ព្រមទាំងអាចត្រូវត្រួតពិនិត្យឡើងវិញបានដោយយន្តការយុត្តិធម៌។ រដ្ឋភាគីគួរតែធានាថា ការត្រួតពិនិត្យឡើងវិញ និងវិសោធនកម្មនៃច្បាប់ទាំងនេះ ត្រូវបានធ្វើឡើងដោយបើកចំហរ តម្លាភាព និងមានដំណើរការពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងភាគីពាក់ព័ន្ធនានា រួមទាំងសង្គមស៊ីវិលផងដែរ។

### ការប្រយុទ្ធប្រឆាំងនឹងនិទណ្ឌភាព និងការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល

១២. គណៈកម្មាធិការសូមធ្វើការបញ្ជាក់ឡើងវិញពីក្តីបារម្ភ អំពីកង្វះខាតនៃដំណើរវិវត្តក្នុងការស៊ើបអង្កេត និងកាត់ទោសករណីរំលោភសិទ្ធិមនុស្សកាលពីអតីតកាល រួមទាំងការសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការបាត់ខ្លួនដោយបង្ខំ ដែលបានកើតឡើងក្រោយពីការចុះសន្ធិសញ្ញាទីក្រុងប៉ារីស ឆ្នាំ១៩៩១។ គណៈកម្មាធិការក៏មានក្តីបារម្ភពីការខ្វះខាតសកម្មភាពរបស់រដ្ឋភាគី ដែលក្នុងនោះរួមមានតុលាការក្នុងស្រុក ក្នុងការឆ្លើយតបទៅនឹងការបញ្ចប់រឿងក្តីនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដោយមិនមានការសិក្សាវាយតម្លៃពីគុណសម្បត្តិ ដែលអាចនឹងបន្សល់ទុកនូវសំណុំរឿងរំលោភសិទ្ធិមនុស្សពីអតីតកាល ដោយមិនបានដោះស្រាយ (មាត្រា២, ៦-៧ និង១៤)។

**១៣. គណៈកម្មាធិការបញ្ជាក់ឡើងវិញពីអនុសាសន៍ទាំងឡាយនាពេលកន្លងមក ពាក់ព័ន្ធនឹងនិទណ្ឌភាពចំពោះការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ។[7] រដ្ឋភាគីគួរតែគោរពតាមកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេតលើការរំលោភសិទ្ធិមនុស្សពីអតីតកាល ដែលបានកើតឡើងក្នុងរបប ប៉ុល ពត និងក្រោយពេលចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស កាត់ទោសជនល្មើស ដោយដាក់ទោសពួកគេឱ្យសមាមាត្រនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មទាំងនោះក្នុងពេលសមស្របណាមួយ និងផ្តល់ការជួសជុលពេញលេញ រួមទាំងសំណងគ្រប់គ្រាន់ដល់គ្រួសារជនរងគ្រោះ។**

---

[6] CCPR/C/128/2
[7] CCPR/C/KHM/CO/2 កថាខណ្ឌ១១

## ការមិនរើសអើង

១៤. គណៈកម្មាធិការនៅតែមានកង្វល់អំពីការរើសអើង និងការផាត់ចេញជាប្រព័ន្ធ ដែលជនជាតិភាគតិចបានជួបប្រទះ ជាពិសេស ខ្មែរក្រោម និងជនជាតិខ្មែរដើមកំណើតវៀតណាម រួមមានការមិនផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលនាំដល់ការរឹតត្បិតក្នុងការទទួលបានសិទ្ធិដទៃទៀតរបស់ពួកគេ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរ អំពីការរើសអើង ការបែងចែក និងការមាក់ងាយដល់ជនមានពិការភាព ក៏ដូចជាក្រុមអ្នកស្រឡាញ់ភេទដូចគ្នា ដែលជារឿយៗក៏រួមទាំងអំពើហិង្សា (មាត្រា២ និង ២៦)។

១៥. **រដ្ឋភាគីគួរតែ ៖**

(ក) អនុម័តច្បាប់ដែលគ្រប់ជ្រុងជ្រោយមួយហាមឃាត់ការរើសអើង រួមមានការរើសអើងតាមផ្នែកផ្សេងៗ ដោយផ្ទាល់ និងដោយប្រយោលនៅគ្រប់វិស័យ ទាំងសាធារណៈនិងឯកជន ដោយផ្អែកលើមូលដ្ឋានទាំងឡាយដែលបានហាមឃាត់នៅក្នុងកតិកាសញ្ញានេះ រួមមាន ជាតិសាសន៍ ពណ៌សម្បុរ ភេទ គំនិតនយោបាយ ឬគំនិតផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ពិការភាព ឬស្ថានភាពដទៃទៀត ព្រមទាំងធានាការទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងសមស្របសម្រាប់ជនរងគ្រោះនៃការរើសអើង។

(ខ) ដាក់ចេញនូវវិធានការនានាប្រកបដោយប្រសិទ្ធភាព ដើម្បីប្រឆាំងនឹងការរើសអើង និងការផាត់ចេញប្រឆាំងនឹងជនជាតិភាគតិច ជាពិសេស ខ្មែរក្រោមនិងជនជាតិខ្មែរដើមកំណើតវៀតណាម រួមទាំងការធានាថាពួកគេទទួលបានឯកសារបញ្ជាក់អត្តសញ្ញាណ។

(គ) បង្ការការរើសអើង និងអំពើហិង្សាប្រឆាំងនឹងក្រុមអ្នកស្រឡាញ់ភេទដូចគ្នា និងជនមានពិការភាព រួមទាំងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ ដើម្បីប្រយុទ្ធប្រឆាំងនឹងការមាក់ងាយពីសង្គមទៅលើពួកគេ។

## សមភាពយេនឌ័រ

១៦. គណៈកម្មាធិការនៅតែមានកង្វល់អំពីការបន្តនៃនិយាមដែលមានលក្ខណៈរើសអើង និងផ្នត់គំនិតផ្នែកយេនឌ័រ ពាក់ព័ន្ធនឹងតួនាទីស្ត្រីក្នុងសង្គម។ គណៈកម្មាធិការក៏កត់សម្គាល់ជាមួយនឹងកង្វល់ផងដែរ អំពីចំនួនតំណាងស្ត្រីមានតិចតួច ដែលនៅតែបន្តមាននៅក្នុងតួនាទីជាអ្នកដឹកនាំ និងតួនាទីធ្វើសេចក្តីសម្រេចចិត្តនៅគ្រប់កម្រិតនៃជីវិតសាធារណៈ។ បន្ថែមលើនេះ គណៈកម្មាធិការក៏មានកង្វល់ថា ច្បាប់ការងារឆ្នាំ១៩៩៧ មិនបានបញ្ចូលគោលការណ៍ស្តីពីការទទួលបានប្រាក់ខែស្មើគ្នាសម្រាប់ការងារដែលមានតម្លៃស្មើគ្នា និងថាច្បាប់នេះមិនបានការពារអ្នកធ្វើការងារតាមផ្ទះ ដែលភាគច្រើនជាស្ត្រី (មាត្រា៣)។

១៧. **រដ្ឋភាគីគួរតែពង្រឹងវិធានការនានាដែលមានគោលបំណងធានាសមភាពយេនឌ័រ រួមមានតាមរយៈ ៖**

(ក) ធានាថាច្បាប់និងគោលនយោបាយទាំងឡាយស្ដីពីសមភាពយេនឌ័រ ត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព និងពិនិត្យឡើងវិញលើច្បាប់ការងារ ឆ្នាំ១៩៩៧ ក្នុងគោលបំណងធានាការអនុវត្តគោលការណ៍ស្ដីពីការទទួលបានប្រាក់ខែស្មើគ្នាសម្រាប់ការងារមានតម្លៃស្មើគ្នា ព្រមទាំងការធានានូវការការពារពេញលេញដល់អ្នកធ្វើការងារតាមផ្ទះ។

(ខ) លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីគោលការណ៍សមភាពរវាងស្ត្រីនិងបុរស និងតម្រូវការក្នុងការលុបបំបាត់ផ្នត់គំនិតផ្នែកយេនឌ័រ ព្រមទាំងធានាថាប្រព័ន្ធផ្សព្វផ្សាយទាំងឡាយលើកកម្ពស់រូបភាពវិជ្ជមានរបស់ស្ត្រី ក្នុងនាមជាអ្នកចូលរួមដ៏សកម្មក្នុងជីវិតសាធារណៈ និងនយោបាយ។

(គ) បង្កើនកិច្ចប្រឹងប្រែងរបស់ខ្លួន ដើម្បីធ្វើឱ្យសម្រេចឱ្យបាននូវការចូលរួមពេញលេញនិងស្មើភាពរបស់ស្ត្រីក្នុងជីវិតនយោបាយ និងសាធារណៈ ក្នុងរយៈពេលកំណត់ជាក់លាក់ រួមមានក្នុងរដ្ឋសភា តួនាទីតាមក្រសួង រាជធានី/ក្រុងតាមតំបន់ និងមូលដ្ឋាន និងតុលាការ ជាពិសេស ក្នុងតួនាទីធ្វើសេចក្ដីសម្រេចចិត្ត។

អំពើហិង្សាប្រឆាំងនឹងនារីភេទ

១៨. ខណៈដែលគណៈកម្មាធិការកត់សម្គាល់លើកិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាប្រឆាំងនឹងនារីភេទ គណៈកម្មាធិការនៅតែមានកង្វល់ចំពោះការពន្យារពេលក្នុងការពិភាក្សា និងការអនុម័តវិសោធនកម្មច្បាប់ ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ដែលមានគម្លាត មួយចំនួនឈានទៅដល់ការធ្វើឱ្យជនទាំងឡាយដែលសិទ្ធិពួកគេត្រូវបានរំលោភ ក្លាយជាជនរងគ្រោះម្ដងទៀត និងការរឹតត្បិតលើការទទួលបានយុត្តិធម៌។ គណៈកម្មាធិការក៏កត់សម្គាល់ជាមួយនឹងកង្វល់ផងដែរ អំពីភាពទូទៅនៃការអត់ឱនរបស់សង្គមចំពោះការប្រើអំពើហិង្សាប្រឆាំងនឹងនារីភេទ និងការអនុវត្តការបន្ទោសជនរងគ្រោះ។ គណៈកម្មាធិការសោកស្ដាយដោយខ្វះព័ត៌មានអំពីចំនួនពាក្យបណ្ដឹង ការចោទប្រកាន់ និងការផ្ដន្ទាទោស ពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំងនឹងនារីភេទ (មាត្រា ២-៣, ៦-៧ និង ២៦)។

១៩. ដោយរំឭកឡើងវិញពីអនុសាសន៍របស់គណៈកម្មាធិការនាពេលកន្លងមក ស្ដីពីអំពើហិង្សាផ្អែកលើយេនឌ័រ[8] រដ្ឋភាគីគួរតែចាត់វិធានការផ្សេងៗដើម្បីធានាថា ច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ ត្រូវបានពិនិត្យឡើងវិញ និងធ្វើវិសោធនកម្ម ដើម្បីផ្ដល់និយមន័យ និងដាក់ទោសឱ្យបានគ្រប់ជ្រោយលើអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងធានាការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព អនុលោមតាមកតិកាសញ្ញានេះ និងបទដ្ឋានអន្តរជាតិដទៃទៀត។ រដ្ឋភាគីគួរតែធានាផងដែរថា រាល់ករណីអំពើហិង្សាប្រឆាំងនឹងនារីភេទ ត្រូវបានស៊ើបអង្កេតយ៉ាងហ្មត់ចត់ ជនល្មើសត្រូវបានកាត់ទោស និងប្រសិនបើមានទោស ត្រូវដាក់ឱ្យសមាមាត្រ និងថាជនរងគ្រោះត្រូវទទួលបានដំណោះស្រាយប្រកបដោយប្រសិទ្ធភាព ទទួលបានការជួសជុលពេញលេញ រួមទាំងសំណងគ្រប់គ្រាន់ ព្រមទាំងទទួលបានការការពារ និងជំនួយគ្រប់គ្រាន់។ រដ្ឋភាគីគួរតែបន្តធ្វើយុទ្ធនាការលើកកម្ពស់ការយល់ដឹង ស្ដីពីអំពើហិង្សាប្រឆាំងនឹងនារីភេទដល់សាធារណជន និងធានាថាអ្នកមានមុខងារផ្សេងៗនៅក្នុងប្រព័ន្ធច្បាប់ រួមមាន ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីអនុវត្តច្បាប់ ទទួលបានការបណ្ដុះបណ្ដាលពាក់ព័ន្ធនឹងបញ្ហានេះ។

[8] Ibid., para. 10.

សិទ្ធិរស់រានមានជីវិត

២០. គណៈកម្មាធិការមានកង្វល់យ៉ាងខ្លាំងអំពីការចោទប្រកាន់ជាច្រើន និងធ្ងន់ធ្ងរ ពាក់ព័ន្ធទៅនឹងការសម្លាប់ក្រៅប្រព័ន្ធតុលាការ ដែលកើតមានលើថ្នាក់ដឹកនាំបក្សប្រឆាំង អ្នកការពារសិទ្ធិមនុស្ស អ្នកកាសែត និងសកម្មជនដីធ្លី នៅក្នុងរដ្ឋភាគី រួមទាំងការសម្លាប់សមាជិកគណបក្សប្រឆាំងម្នាក់ឈ្មោះ ស៊ិន ខុន ក្នុងខែវិច្ឆិកា ឆ្នាំ ២០២១។ គណៈកម្មាធិការក៏មានកង្វល់ផងដែរអំពី កង្វះការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងមិនលំអៀងលើករណីសម្លាប់ទាំងនេះ ដែលនៅតែមិនទាន់បានដោះស្រាយនៅឡើយ (មាត្រា៦)។

២១. **ជាអាទិភាព រដ្ឋភាគីគួរតែធានាថារាល់ការចោទប្រកាន់ពីការសម្លាប់ក្រៅប្រព័ន្ធតុលាការ ត្រូវបានស៊ើបអង្កេតភ្លាមៗ ដោយមិនលំអៀង និងយ៉ាងហ្មត់ចត់។ ជនល្មើសទាំងអស់ ដោយមិនគិតពីតួនាទី ឬមុខតំណែងផ្លូវការ ត្រូវបានផ្តន្ទាទោស និងថាប្រសិនបើមានទោស ត្រូវដាក់ទោសឱ្យសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត។ រដ្ឋភាគីគួរតែចាត់រាល់វិធានការចាំបាច់ ដើម្បីបង្ការការសម្លាប់បែបនេះ កំណត់ស្វែងរកការពិត និងផ្តល់ការជួសជុលពេញលេញដល់គ្រួសារជនរងគ្រោះ។**

ការហាមឃាត់អំពើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត

២២. គណៈកម្មាធិការកត់សម្គាល់ជាមួយនឹងកង្វល់ថា ខណៈដែលមាត្រា ២១០ នៃក្រមព្រហ្មទណ្ឌហាមឃាត់អំពើទារុណកម្ម និងអំពើឃោរឃៅ តែបទប្បញ្ញត្តិនេះមិនបានចែងពីនិយមន័យផ្លូវច្បាប់មួយស្តីពីទារុណកម្ម និងការប្រព្រឹត្តមិនគប្បីនោះទេ។ គណៈកម្មាធិការក៏មានកង្វល់ផងដែរជុំវិញការចោទប្រកាន់នានាអំពីកង្វះឯករាជ្យភាព នៃគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត ក៏ដូចជា អំពីលទ្ធភាពមានកម្រិតរបស់គណៈកម្មាធិការនេះ ក្នុងការធ្វើទស្សនកិច្ចតាមពន្ធនាគារ និងសម្ភាសន៍ជនជាប់ឃុំ។ បន្ថែមលើនេះ គណៈកម្មាធិការមានកង្វល់យ៉ាងខ្លាំងអំពីការចោទប្រកាន់ពីអំពើទារុណកម្ម និងការប្រព្រឹត្តិមិនគប្បីដ៏ធ្ងន់ធ្ងរ ដែលកើតមាននៅក្នុងកន្លែងឃុំឃាំងរបស់នគរបាល និងកន្លែងឃុំឃាំងផ្សេងៗទៀត ដែលករណីខ្លះបានឈានទៅដល់ការបាត់បង់ជីវិត (មាត្រា៦-៧ និង ៩-១០)។

២៣. **រដ្ឋភាគីគួរតែចាត់វិធានការបន្ទាន់ និងរឹងមាំ ដើម្បីលុបបំបាត់អំពើទារុណកម្ម និងការប្រព្រឹត្តិមិនគប្បី រួមមានតាមរយៈ៖**

**(ក) កែសម្រួលច្បាប់នានាក្នុងគោលបំណងធានាថា ច្បាប់មានចែងអំពីនិយមន័យទារុណកម្ម ដែលស្របទាំងស្រុងទៅនឹងមាត្រា ១ នៃអនុសញ្ញាប្រឆាំងទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត និងមាត្រា ៧ នៃកតិកាសញ្ញានេះ។**

**(ខ) បង្កលក្ខណៈឱ្យគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត អាចអនុវត្តមុខងាររបស់ខ្លួនដោយឯករាជ្យ និងយ៉ាងមានប្រសិទ្ធភាព រួមទាំងការចុះទស្សនកិច្ចរាល់កន្លែងឃុំឃាំងជាទៀងទាត់ និងមិនចាំបាច់ជូនដំណឹងជាមុន។**

(គ) ធ្វើការស៊ើបអង្កេតភ្លាមៗ ដោយហ្មត់ចត់ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមិនលំអៀង រាល់ការចោទប្រកាន់ទាំងឡាយអំពីអំពើទារុណកម្ម និងការប្រព្រឹត្តិមិនគប្បី ស្របតាមគោលការណ៍ណែនាំសម្រាប់ការស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាព និងការចងក្រងឯកសារនៃអំពើទារុណកម្ម និងអំពើឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប ឬទណ្ឌកម្មដទៃទៀត (ពិធីសារអ៊ីស្តង់ប៊ុល) ដោយធានាថា ជនល្មើសទាំងអស់ត្រូវបានកាត់ទោស ហើយប្រសិនបើមានទោស ត្រូវដាក់ទោសឱ្យបានសមស្រប និងថាជនរងគ្រោះទទួលបានការជួសជុលពេញលេញ។

(ឃ) ធានាការការពារដើមបណ្តឹងពីការសងសឹក និងធានាថាករណីនៃការសងសឹកណាមួយត្រូវបានស៊ើបអង្កេត និងជនល្មើសត្រូវបានកាត់ទោស ហើយប្រសិនបើមានទោស ត្រូវដាក់ទោសឱ្យបានសមស្រប។

លក្ខខណ្ឌនៃការឃុំខ្លួន

២៤. ខណៈដែលកត់សម្គាល់ពីកិច្ចប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការកាត់បន្ថយភាពចង្អៀតណែន និងកែលម្អលក្ខខណ្ឌនៅក្នុងកន្លែងឃុំខ្លួន គណៈកម្មាធិការនៅតែមានកង្វល់ចំពោះរបាយការណ៍ជាច្រើនដែលបង្ហាញថាចំនួនអ្នកជាប់ឃុំនៅក្នុងពន្ធនាគារបាន និងកំពុងកើនឡើងគួរឱ្យកត់សម្គាល់ ដែលជាមធ្យមពន្ធនាគារមួយផ្ទុកអ្នកជាប់ឃុំលើស ៣០០ ភាគរយ នៃសមត្ថភាពផ្ទុក។ គណៈកម្មាធិការក៏កត់សម្គាល់ជាមួយនឹងកង្វល់ផងដែរ ដែលអ្នកជាប់ឃុំជាច្រើនមិនទទួលបានអាហារ ទឹកស្អាត និងការព្យាបាលវេជ្ជសាស្ត្រគ្រប់គ្រាន់។ បន្ថែមលើនេះ គណៈកម្មាធិការក៏មានកង្វល់អំពីរបាយការណ៍នានាស្តីពីការរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងពន្ធនាគារដែលចង្អៀតណែន ដោយអ្នកជាប់ឃុំមិនទទួលបានការព្យាបាលវេជ្ជសាស្ត្រ និងការធ្វើតេស្តឱ្យបានគ្រប់គ្រាន់ (មាត្រា ៧ និង ១០)។

២៥. រដ្ឋភាគីគួរតែបង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនដើម្បីធានាថាលក្ខខណ្ឌនៃការឃុំឃាំង គឺអនុលោមតាមស្តង់ដារសិទ្ធិមនុស្សអន្តរជាតិដែលពាក់ព័ន្ធ រួមទាំងវិធានអង្គការសហប្រជាជាតិ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការប្រព្រឹត្តិទៅលើជនជាប់ឃុំ (វិធាននែលសាន់ម៉ាន់ដឺឡា) ។ ជាពិសេសរដ្ឋភាគីគួរតែ ៖

(ក) កាត់បន្ថយនូវភាពចង្អៀតណែននៅក្នុងពន្ធនាគារឱ្យបានច្រើន ជាពិសេសតាមរយៈការអនុវត្តវិធានការមិនឃុំខ្លួនឱ្យកាន់តែទូលំទូលាយ ដែលជាជម្រើសជំនួសការជាប់ពន្ធនាគារ។

(ខ) ពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកែលម្អលក្ខខណ្ឌនៃការឃុំឃាំង និងធានាឱ្យមានលទ្ធភាពទទួលបានអាហារ ទឹកស្អាត និងការថែទាំសុខភាពគ្រប់គ្រាន់សម្រាប់អ្នកជាប់ឃុំនៅគ្រប់ទីកន្លែងនៃការដកហូតសេរីភាព ជាពិសេសនៅកន្លែងឃុំឃាំងដែលមានការផ្ទុះឡើងនៃមេរោគកូវីដ-១៩។

សេរីភាព និងសុវត្ថិភាពរបស់មនុស្ស

២៦. គណៈកម្មាធិការមានការព្រួយបារម្ភអំពីចំនួនអ្នកដែលស្ថិតក្នុងការឃុំខ្លួនបណ្តោះអាសន្នជាច្រើន រួមទាំងស្ត្រីដែលមានកូនតូចផងដែរ ដែលជារឿយៗត្រូវបានឃុំខ្លួនរួមជាមួយទណ្ឌិត។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរ អំពីរបាយការណ៍ដែលថាការការពារផ្នែកច្បាប់ជាមូលដ្ឋានសម្រាប់ជនដែលត្រូវបានដកហូតសិទ្ធិសេរីភាព ជារឿយៗមិនត្រូវបានគោរព រួមទាំងសិទ្ធិទទួលបានព័ត៌មានអំពីការចោទប្រកាន់ប្រឆាំងនឹងពួកគេ

សិទ្ធិទទួលបានមេធាវី និងវេជ្ជបណ្ឌិតភ្លាមៗតាមជម្រើសរបស់ពួកគេ និងសិទ្ធិជូនដំណឹងដល់បុគ្គលម្នាក់តាមការជ្រើសរើសរបស់ពួកគេអំពីការឃុំខ្លួននេះ (មាត្រា ៩-១០ និង ១៤)។

២៧. រដ្ឋភាគីគួរតែចាត់វិធានការផ្លូវច្បាប់ និងវិធានការផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ដើម្បីធានាថាការឃុំខ្លួនបណ្តោះអាសន្ននឹងអាចត្រូវបានប្រើជាវិធានការពិសេស និងមានពេលកំណត់ច្បាស់លាស់ ជាពិសេសចំពោះម្តាយដែលមានកូនតូច និងបង្កើនការប្រើប្រាស់វិធានការនានាជំនួសឱ្យការឃុំឃាំងបណ្តោះអាសន្ន។ រដ្ឋភាគីគួរតែធានាថា ការការពារផ្លូវច្បាប់ទាំងអស់ ត្រូវបានធានាក្នុងការអនុវត្តចំពោះបុគ្គលទាំងអស់ដែលត្រូវបានដកហូតសិទ្ធិសេរីភាពតាំងពីខណៈពេលដំបូងនៃការឃុំខ្លួន រួមទាំងតាមរយៈការអនុម័តជាផ្លូវការនូវសេចក្តីព្រាងគោលនយោបាយជំនួយផ្នែកច្បាប់ ដើម្បីធានាថាជំនួយផ្នែកច្បាប់មានសម្រាប់បុគ្គលទាំងអស់ដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម។

ការចាប់ខ្លួន និងការឃុំខ្លួនដោយបំពាន

២៨. ខណៈដែលគណៈកម្មាធិការកត់សម្គាល់លើការពន្យល់ដែលផ្តល់ដោយប្រតិភូ គណៈកម្មាធិការនៅតែមានការព្រួយបារម្ភថាអ្នករងគ្រោះដោយសារគ្រឿងញៀនអាចត្រូវបានដកហូតសេរីភាព និងតម្រូវឱ្យទទួលនូវការស្តារនីតិសម្បទាដោយបង្ខំ ស្របតាមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរថាជនដែលគ្មានទីលំនៅ អ្នកសុំទាន កុមារដែលរស់នៅតាមដងផ្លូវ និងជនមានពិការភាពផ្លូវចិត្ត ត្រូវបានឃុំខ្លួនដោយបំពាន និងបង្ខំឱ្យស្នាក់នៅក្នុងមជ្ឈមណ្ឌលសំចតសង្គមកិច្ច រាជធានីភ្នំពេញ (មណ្ឌលព្រៃស្ពឺ) ដែលប្រតិបត្តិការដោយពុំមានក្របខ័ណ្ឌបទប្បញ្ញត្តិច្បាស់លាស់ (មាត្រា ៩-១០)។

២៩. រដ្ឋភាគីគួរ ៖

(ក) បន្តការពិនិត្យឡើងវិញនូវច្បាប់ គោលនយោបាយ និងការអនុវត្តនានាដែលពាក់ព័ន្ធនឹងអ្នកប្រើគ្រឿងញៀន ជាពិសេសចំពោះបុគ្គលដែលត្រូវបានដកហូតសេរីភាពនៅក្នុងមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាគ្រឿងញៀន ក្នុងគោលបំណងនាំធ្វើឱ្យលិខិតបទដ្ឋានគតិយុត្ត និងការអនុវត្តទាំងនោះអនុលោមពេញលេញជាមួយនឹងកតិកាសញ្ញា។

(ខ) បញ្ចប់ការឃុំខ្លួនដោយមិនស្ម័គ្រចិត្ត ចំពោះជនអនាថា អ្នកសុំទាន និងជនមានពិការភាពផ្លូវចិត្តដែលត្រូវបានទុកឱ្យរស់នៅក្នុងមណ្ឌលសំចតឬមណ្ឌលស្តារនីតិសម្បទា និងចាត់វិធានការសមស្របដើម្បីផ្តល់ជម្រើសចំពោះការដាក់កុមាររស់នៅតាមដងផ្លូវក្នុងមណ្ឌល ដោយរួមបញ្ចូលការដាក់ពួកគេនៅក្នុងកន្លែងដែលមានលក្ខណៈបែបគ្រួសារ។

(គ) អនុម័តក្របខណ្ឌច្បាប់ច្បាស់លាស់ និងមានតម្លាភាព ដើម្បីធានាថាប្រព័ន្ធគាំទ្រសង្គមគ្រប់គ្រាន់ត្រូវបានផ្តល់ជូនប្រជាពលរដ្ឋដែលពិតជាត្រូវការជំនួយ រួមទាំងច្បាប់ស្តីពីការប្រព្រឹត្តិទៅនៃមណ្ឌលព្រៃស្ពឺ។

ការជួញដូរមនុស្ស

៣០. ទោះបីជាមានការខិតខំប្រឹងប្រែងជាច្រើនពីរដ្ឋភាគី ក្នុងការលុបបំបាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារក៏ដោយ គណៈកម្មាធិការនៅតែមានការព្រួយបារម្ភពីរបាយការណ៍អំពីកង្វះការការពារសម្រាប់ជនរងគ្រោះនៃការជួញដូរ ជាពិសេសស្ត្រី និងកុមារ។ គណៈកម្មាធិការក៏មានការព្រួយបារម្ភផងដែរអំពីករណីបញ្ចាំខ្លួនដោះបំណុលដោយរួមទាំងកុមារ ជាពិសេសនៅក្នុងឧស្សាហកម្មឥដ្ឋ (មាត្រា៨ និង២៦)។

**៣១. រដ្ឋភាគីគួរធានានូវប្រសិទ្ធិភាពនៃការពង្រឹងការអនុវត្តច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ។ រដ្ឋភាគីគួរធានាឱ្យបានថា គ្រប់ករណីជួញដូរមនុស្សទាំងអស់ត្រូវបានស៊ើបអង្កេតយ៉ាងលម្អិត ហើយបុគ្គលដែលទទួលខុសត្រូវលើករណីទាំងនោះនឹងត្រូវបានកាត់ទោស ហើយប្រសិនបើរកឃើញថាមានទោស ត្រូវទទួលរងការវិនិច្ឆ័យទោសសមស្រប ចំណែកជនរងគ្រោះត្រូវតែទទួលបានសំណងពេញលេញ ព្រមទាំងការការពារ និងជំនួយសមស្រប។ រដ្ឋភាគីគួរលុបបំបាត់នូវរាល់គ្រប់ទម្រង់នៃពលកម្មកុមារដោយបង្ខំ ជាពិសេសនៅតាមឧស្សាហកម្មឥដ្ឋ រួមទាំងពង្រឹងបន្ថែមនូវសមត្ថភាពរបស់បុគ្គលិកចុះអធិការកិច្ច ដើម្បីឱ្យពួកគាត់អាចអនុវត្តការងាររបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព នៅក្នុងវិស័យដែលបញ្ហានេះកើតមានឡើងជាទូទៅ។**

ឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌

៣២. បើទោះបីជាមានយន្តការមួយចំនួន ត្រូវបានអនុវត្តដោយរដ្ឋភាគីក្នុងការពង្រឹងឯករាជ្យភាពនៅក្នុងប្រព័ន្ធយុត្តិធម៌ក្តី ក៏គណៈកម្មាធិការនៅតែមានក្តីបារម្ភពីឯករាជ្យភាព និងភាពលំអៀងរបស់ប្រព័ន្ធយុត្តិធម៌ និងពីអត្រាខ្ពស់នៃការចោទប្រកាន់ពីភាពពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌។ គណៈកម្មាធិការក៏បានកត់សម្គាល់ដោយក្តីបារម្ភចំពោះចៅក្រមមួយចំនួនដែលជាសមាជិកនៃគណបក្សកាន់អំណាច ដែលជាញឹកញាប់មានតួនាទីជាថ្នាក់ដឹកនាំ ហើយអាចធ្វើឱ្យប៉ះពាល់ដល់ឯករាជ្យភាពរបស់ពួកគាត់ (មាត្រា ១៤)។

**៣៣. រដ្ឋភាគីគួរអនុវត្តរាល់យន្តការទាំងផ្លូវច្បាប់ និងការអនុវត្ត ដើម្បីធានាបាននូវ ឯករាជ្យភាព មានមិនលំអៀង និងសុវត្ថិភាពរបស់អង្គចៅក្រម និងព្រះរាជអាជ្ញា។ រដ្ឋភាគីគួរមានយន្តការច្បាស់លាស់ដើម្បីរារាំងមិនឱ្យចៅក្រមរងឥទ្ធិពលនយោបាយក្នុងការសម្រេចចិត្ត រួមទាំងការធានាឱ្យបាននូវដំណើរការជ្រើសរើស ការតែងតាំង ការផ្អាកតួនាទី ការបញ្ឈប់ និងការពិន័យទៅលើអង្គចៅក្រម និងព្រះរាជអាជ្ញា ដោយអនុលោមទៅតាមបទប្បញ្ញត្តិនៃកតិកាសញ្ញានេះ និងស្តង់ដារអន្តរជាតិដែលពាក់ព័ន្ធផ្សេងទៀត។**

សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

៣៤. គណៈកម្មាធិការនៅតែបន្តមានក្តីបារម្ភ អំពីការរឹតត្បិតសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិដែលកើតមានជាបន្តបន្ទាប់នៅក្នុងរដ្ឋភាគី។ គណៈកម្មាធិការមានការភ្ញាក់ផ្អើល ពេលមានរបាយការណ៍ដែលបង្ហាញពីការបិទទីភ្នាក់ងារសារព័ត៌មានជាតិ និងអន្តរជាតិ ការបិទខ្ទប់គេហទំព័រដែលរិះគន់រដ្ឋាភិបាល ការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌ និងរដ្ឋប្បវេណីចំពោះអ្នកសារព័ត៌មាន និងអ្នកការពារសិទ្ធិមនុស្ស ការរីករាលដាលនៃការបៀតបៀន និងការបំភិតបំភ័យទៅលើសកម្មជនអនឡាញ រួមបញ្ចូលទាំងអំឡុងពេលបោះឆ្នោត ឆ្នាំ២០១៨ និងដោយសារការ

រិះគន់រដ្ឋភាគីទៅលើយន្តការដោះស្រាយវិបត្តិកូវីដ១៩។ គណៈកម្មាធិការបានកត់សម្គាល់ដោយក្តីបារម្ភចំពោះបទចោទប្រកាន់ព្រហ្មទណ្ឌមួយចំនួនស្ថិតក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ រួមទាំងការបរិហារកេរ្តិ៍ ការញុះញង់ ការប្រមាថ និងការប្រមាថព្រះមហាក្សត្រ ដែលជាញឹកញាប់ត្រូវបានប្រើដើម្បីរិតត្បិតដោយមិនសមរម្យឬហួសហេតុ ទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ មិនតែប៉ុណ្ណោះ គណៈកម្មាធិការបារម្ភពីអនុក្រឹតស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ និងសេចក្តីព្រាងច្បាប់ថ្មីៗ រួមទាំងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងការទទួលបានព័ត៌មាន និងវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន ដែលបានបង្កក្តីបារម្ភយ៉ាងខ្លាំងចំពោះការរិតត្បិតកាន់តែធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងដែលត្រូវបានរៀបចំឡើងដោយមិនមានការពិគ្រោះយោបល់ជាមួយសង្គមស៊ីវិល និងភាគីពាក់ពន្ធនានា (មាត្រា១៩)។

៣៥. គណៈកម្មាធិការ សូមបញ្ជាក់ឡើងវិញអំពីអនុសាសន៍កន្លងមកស្តីពីសេរីភាពនៃការបញ្ចេញមតិ និងជំរុញរដ្ឋភាគីចាត់វិធានការបន្ទាន់ដើម្បីធានាថាជនគ្រប់រូបអាចប្រើប្រាស់សិទ្ធិដោយសេរីក្នុងការបញ្ចេញមតិ ដោយយោងតាមមាត្រា១៩ នៃកតិកាសញ្ញា និងសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការ លេខ៣៤ (២០១១) ស្តីពីសេរីភាពនៃគំនិត និងការសម្តែងមតិ។ ដើម្បីធ្វើដូចនេះបាន រដ្ឋភាគីត្រូវ ៖

(ក) ជៀសវាងការផ្តន្ទាទោស និងដាក់ពន្ធនាគារអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងតួអង្គសង្គមស៊ីវិលផ្សេងទៀត ដែលការផ្តន្ទាទោស និងដាក់ពន្ធនាគារជាមធ្យោបាយរារាំង ឬបំបាក់ទឹកចិត្តក្រុមទាំងនោះពីការបញ្ចេញមតិយោបល់ដោយសេរី។

(ខ) បង្ការរាល់សកម្មភាពឃាយី និងការគំរាមកំហែង ការរឹតបន្តឹងតាមទំនើងចិត្ត ការចាប់ខ្លួនអ្នកសារព័ត៌មាន សកម្មជន និងអ្នកការពារសិទ្ធិមនុស្ស ដែលគ្រាន់តែរិះគន់មន្ត្រីសាធារណៈ ឬគោលនយោបាយរាជរដ្ឋាភិបាល។

(គ) លុបបទការបរិហារកេរ្តិ៍ចេញពីបទល្មើសព្រហ្មទណ្ឌ និងរាល់បទប្បញ្ញត្តិទាក់ទងនៅក្នុងក្រមព្រហ្មទណ្ឌ និងច្បាប់ស្តីពីទូរគមនាគមន៍ ឱ្យស្របនឹងមាត្រា១៩ នៃកតិកាសញ្ញា។

(ឃ) ពិនិត្យឡើងវិញ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្នដែលកំពុងរងចាំការអនុម័ត រួមមានអនុក្រឹត្យស្តីពីការបង្កើតច្រកទ្វារអ៊ីនធឺណិតជាតិ សេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីរបបសារព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដើម្បីជៀសវាងការប្រើវាក្យស័ព្ទមិនច្បាស់លាស់ និងការរិតត្បិតទូលំទូលាយ។

(ង) ធានាថារាល់ការតាក់តែង និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តនានា រួមទាំងប្រកាសក្រសួង រាល់ការដាក់កំហិតលើការអនុវត្តសេរីភាពនៃការបញ្ចេញមតិ និងការជួបប្រជុំ ត្រូវអនុលោមតាមតម្រូវការដ៏តឹងរឹងនៃមាត្រា ១៩ (៣) និងមាត្រា ២២ នៃកតិកាសញ្ញានេះ។

*សិទ្ធិជួបជុំដោយសន្តិវិធី និងសេរីភាពនៃសមាគម*

៣៦. គណៈកម្មាធិការព្រួយបារម្ភយ៉ាងខ្លាំង អំពីរបាយការណ៍នៃការបដិសេធក្នុងការអនុញ្ញាតឱ្យមានជួបប្រជុំដោយសន្តិវិធីដោយមិនសមហេតុផល និងការចាប់ខ្លួនអ្នករៀបចំផ្អែកលើបទប្បញ្ញត្តិច្បាប់មិនច្បាស់លាស់ដែលមានចែងក្នុងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី។ គណៈកម្មាធិការព្រួយបារម្ភយ៉ាងខ្លាំងចំពោះព័ត៌មាន

ដែលទទួលបានអំពីការប្រើប្រាស់កម្លាំងលើសលុប និងមិនសមាមាត្រ ដើម្បីបំបែកការធ្វើបាតុកម្មដោយសន្តិវិធី ដែលនាំឱ្យមានការចាប់ខ្លួន និងការឃុំខ្លួនបាតុករជាច្រើន រួមមាន អ្នកការពារសិទ្ធិមនុស្ស សកម្មជនបរិស្ថាន ថ្នាក់ដឹកនាំបក្សប្រឆាំង និងសមាជិកសហជីព (ដូចជា អ្នកទាក់ទងនឹងដែនជម្រកសត្វព្រៃ ព្រៃឡង់ មាតាធម្មជាតិកម្ពុជា សហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍)។ គណៈកម្មាធិការ ក៏បានកត់សម្គាល់ដោយក្តីកង្វល់លើការធ្វើវិសោធនកម្មច្បាប់សហជីព នៅខែមករា ឆ្នាំ២០២០ និងសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ ដែលមានគោលដៅគ្រប់គ្រងការចូលប្រើប្រាស់ និងអាកប្បកិរិយានៅទីធ្លាសាធារណៈ អាចរហូតដល់កំហិតសិទ្ធិនៃការជួបជុំដោយសន្តិវិធី ដោយសារតែពីច្បាប់ទាំងពីរពុំបានផ្តល់នូវនិយមន័យដល់ពាក្យពេចន៍មួយចំនួនឱ្យបានច្បាស់លាស់ ដែលនោះអាចធ្វើឱ្យអាជ្ញាធរបកស្រាយ និងប្រើប្រាស់ច្បាប់នេះខុសពីគោលបំណងដើម។ បន្ថែមលើនេះទៀត គណៈកម្មាធិការក៏បានធ្វើការកត់សម្គាល់ដោយការព្រួយបារម្ភថាច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានដាក់កាតព្វកិច្ចឱ្យអង្គការនានាផ្តល់របាយការណ៍មិនសមហេតុផល ដែលនាំឱ្យមានការបដិសេធការចុះបញ្ជី និងការឈ្លបមើលអ្នកការពារសិទ្ធិមនុស្ស (មាត្រា ២១-២២)។

**៣៧. យោងតាមមាត្រា២១ នៃកតិកាសញ្ញា និងសេចក្តីពន្យល់ទូទៅលេខ៣៧ (២០២០) របស់គណៈកម្មាធិការ ស្តីពីសិទ្ធិជួបជុំដោយសន្តិវិធី រដ្ឋភាគីគួរ ៖**

**(ក) ពន្លឿនការខិតខំប្រឹងប្រែងដើម្បីពិនិត្យឡើងវិញនូវលិខិតបទដ្ឋានគតិយុត្តបច្ចុប្បន្ន ដែលកំពុងរងចាំការអនុម័ត រួមមាន វិសោធនកម្មលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសេចក្តីព្រាងច្បាប់ស្តីពីសណ្តាប់ធ្នាប់សាធារណៈ ក៏ដូចជាការអនុវត្តជាក់ស្តែង ដើម្បីធានាថាបុគ្គលគ្រប់រូបអាចប្រើប្រាស់សិទ្ធិជួបជុំដោយសន្តិវិធីពេញលេញទាំងនៅក្នុងច្បាប់ និងការអនុវត្ត និងដើម្បីធានាថាមានការពិគ្រោះយោបល់លើការពិនិត្យឡើងវិញទាំងអស់ ប្រកបដោយអត្ថន័យ បើកចំហ និងតម្លាភាពជាមួយអង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត។**

**(ខ) ធានាថាការរឹតត្បិតណាមួយលើសិទ្ធិនៃការជួបជុំដោយសន្តិវិធី រួមទាំងតាមរយៈការអនុវត្តការដាក់ទណ្ឌកម្មផ្នែករដ្ឋបាល និងព្រហ្មទណ្ឌប្រឆាំងនឹងបុគ្គលដែលអនុវត្តសិទ្ធិនោះ ត្រូវអនុលោមតាមតម្រូវការដ៏តឹងរឹងនៃមាត្រា ២១ នៃកតិកាសញ្ញា**

**(គ) ស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពរាល់ករណីនៃការចាប់ខ្លួន និងឃុំខ្លួនដោយអំពើចិត្ត លើអ្នកតវ៉ាដោយសន្តិវិធី ក៏ដូចជាអំពើហិង្សាលើពួកគេ ហើយនាំអ្នកទទួលខុសត្រូវមកកាត់ទោស**

**(ឃ) ទប់ស្កាត់រាល់ទម្រង់នៃការយាយី និងការបំភិតបំភ័យសមាជិកអង្គការសង្គមស៊ីវិល សហជីព និងគណបក្សនយោបាយ និងធានាថាពួកគេអាចអនុវត្តសិទ្ធិការងារ និងសកម្មភាពពាក់ព័ន្ធដោយសេរី។**

ការចូលរួមក្នុងកិច្ចការសាធារណៈ

៣៨. គណៈកម្មាធិការមានការព្រួយបារម្ភអំពីការរំលាយគណបក្សនយោបាយប្រឆាំងធំ គឺគណបក្សសង្គ្រោះជាតិ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ និងគណបក្សប្រឆាំងចំនួនបីផ្សេងទៀតនៅឆ្នាំ២០២១ និងការផ្ទេរអាសនៈទាំងអស់របស់គណបក្សសង្គ្រោះជាតិនៅក្នុងរដ្ឋសភាទៅឱ្យគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា ដែលធ្វើឲ្យប៉ះពាល់ដល់សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត។ គណៈកម្មាធិការមានការព្រួយបារម្ភអំពី

ឯករាជ្យភាព និងភាពមិនលំអៀងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងការលំបាកដែលគណបក្សថ្មីត្រូវប្រឈមក្នុងការធ្វើយុទ្ធនាការឃោសនាបោះឆ្នោតដែលស្មើភាព ដោយសេរី និងតម្លាភាព។ គណៈកម្មាធិការសម្តែងការព្រួយបារម្ភយ៉ាងខ្លាំង ចំពោះការដាក់កំហិតមិនស្របច្បាប់មកលើសមាជិកគណបក្សប្រឆាំងទាក់ទងនឹងការចូលរួមរបស់ពួកគេក្នុងកិច្ចការសាធារណៈ និងការបោះឆ្នោត តាមរយៈការគំរាមកំហែង ការយាយី ការចាប់ខ្លួនតាមអំពើចិត្ត ការជំនុំជម្រះក្តីទ្រង់ទ្រាយធំ ការដកហូតលិខិតឆ្លងដែន និងអំពើហិង្សា ដូចជាការសម្លាប់សមាជិកគណបក្សសង្គ្រោះជាតិ គឺលោក ស៊ិន ខុន កាលពីខែវិច្ឆិកា ឆ្នាំ២០២១ (មាត្រា ២, ៦ និង ២៥)។

៣៩. រដ្ឋភាគីគួរធ្វើឱ្យបទប្បញ្ញត្តិ និងការអនុវត្តជុំវិញការបោះឆ្នោត អនុលោមយ៉ាងពេញលេញតាមកតិកាសញ្ញា រួមមានមាត្រា ២៥ ដោយវិធីខាងក្រោម ៖

(ក) បញ្ចប់ការចាប់ខ្លួនតាមអំពើចិត្ត និងអំពើយាយី ការបំភិតបំភ័យ និងអំពើហិង្សាលើសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង

(ខ) ធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ និងឯករាជ្យលើរាល់ការចោទប្រកាន់ពីការយាយី ការបំភិតបំភ័យ និងការចាប់ខ្លួនតាមអំពើចិត្ត និងអំពើហិង្សាលើសមាជិក និងអ្នកគាំទ្រគណបក្សប្រឆាំង ជាពិសេសក្នុងការសម្លាប់លោក ស៊ិន ខុន និងនាំជនល្មើសមកកាត់ទោស

(គ) បញ្ចប់ការជំនុំជម្រះក្តីទ្រង់ទ្រាយធំទាំងអស់ប្រឆាំងនឹងសមាជិកនៃគណបក្សប្រឆាំង និងធានាថាដំណើរការទាំងអស់ដែលបានធ្វើឡើងប្រឆាំងនឹងពួកគេ ក៏ដូចជាប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស គឺស្របតាមការធានាផ្នែកនីតិវិធីទាំងអស់ដែលមានចែងក្នុងកតិកាសញ្ញា

(ឃ) ធានានូវការប្រើប្រាស់សិទ្ធិបោះឆ្នោតដោយជនគ្រប់រូប ដោយពេញលេញ និងប្រកបដោយអត្ថន័យ រួមទាំងបេក្ខជននយោបាយរបស់គណបក្សប្រឆាំង និងគណបក្សនយោបាយទាំងអស់អាចធ្វើយុទ្ធនាការបោះឆ្នោតដោយស្មើភាព សេរី និងតម្លាភាព

(ង) ធានានូវសេរីភាពក្នុងការចូលរួមក្នុងការជជែកដេញដោលនយោបាយពហុនិយម រួមទាំងសម្របសម្រួលការធ្វើបាតុកម្ម និងកិច្ចប្រជុំដោយសន្តិវិធី និងជៀសវាងពីការប្រើប្រាស់ច្បាប់ព្រហ្មទណ្ឌ ដើម្បីគាបសង្កត់សេរីភាព ឬដើម្បីដកចេញបេក្ខជនប្រឆាំងពីដំណើរការបោះឆ្នោត

(ច) ពង្រឹងយន្តការតុលាការ និងការបោះឆ្នោត ដើម្បីធានាដំណើរការបោះឆ្នោតដោយយុត្តិធម៌ ជាពិសេសដើម្បីឱ្យទាន់ពេលវេលាសម្រាប់ការបោះឆ្នោតឃុំសង្កាត់ឆ្នាំ២០២២ និងការបោះឆ្នោតជាតិឆ្នាំ២០២៣។

យុត្តិធម៌អនីតិជន

៤០. ខណៈដែលគណៈកម្មាធិការស្វាគមន៍ការអនុម័តច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ ២០១៦ គណៈកម្មាធិការមានការសោកស្តាយ ដែលការអនុវត្តច្បាប់នេះនៅមានកម្រិត ហើយក្នុងការអនុវត្តជាក់ស្តែង កុមារដែលមានទំនាស់នឹងច្បាប់នៅតែបន្តដាក់ឱ្យនៅក្នុងការឃុំឃាំងបណ្តោះអាសន្ន។ គណៈកម្មាធិការក៏មានការព្រួយបារម្ភអំពីការផ្ទេរកុមារមកពីខេត្តដាច់ស្រយាល ដែលពួកគេពឹងផ្អែកលើជំនួយសម្ភារៈ និងការគាំទ្រផ្នែកផ្លូវចិត្តរបស់

គ្រួសារពួកគេ ទៅកាន់កន្លែងថ្មី មណ្ឌលយុវនីតិសម្បទា នៅខេត្តកណ្ដាលសម្រាប់ការឃុំខ្លួន (មាត្រា ២៣-២៤)។

៤១. **រដ្ឋភាគីគួរពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីធានាការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព និងធានាថាកុមារដែលមានទំនាស់នឹងច្បាប់ត្រូវបានប្រព្រឹត្តិតាមរបៀបដែលសមស្របនឹងអាយុរបស់ពួកគេ។ រដ្ឋភាគីក៏គួរតែធានាថា ការឃុំខ្លួនអនីតិជនបណ្ដោះអាសន្នគួរតែត្រូវបានប្រើយ៉ាងតឹងរឹង នៅក្នុងករណីពិសេស និងត្រូវប្រើតែជាជម្រើសចុងក្រោយប៉ុណ្ណោះ។ រដ្ឋភាគីគួរតែពិចារណាលើការពិនិត្យឡើងវិញឱ្យបានហ្មត់ចត់ ដើម្បីវាយតម្លៃលើជម្រើសផ្សេងទៀតជាជាងការឃុំខ្លួន លើករណីកុមារដែលមានទំនាស់នឹងច្បាប់ដែលនឹងត្រូវផ្ទេរទៅមណ្ឌលយុវនីតិសម្បទា ។**

ជនជាតិដើមភាគតិច

៤២. គណៈកម្មាធិការស្វាគមន៍ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការពង្រឹងយន្តការការពារសិទ្ធិជនជាតិដើមភាគតិច។ ទោះជាយ៉ាងណាក៏ដោយ គណៈកម្មាធិការនៅតែមានការព្រួយបារម្ភចំពោះចំណុចខ្វះខាតក្នុងការអនុវត្តក្របខ័ណ្ឌច្បាប់ និងការការពារសិទ្ធិជនជាតិដើមភាគតិចក្នុងការប្រើប្រាស់ និងកាន់កាប់ដីធ្លី និងទឹកដីរបស់ពួកគេ។ គណៈកម្មាធិការមានការព្រួយបារម្ភថាពុំមានការគោរពជាប្រព័ន្ធលើ សិទ្ធិរបស់ជនជាតិដើមភាគតិច ក្នុងការយល់ព្រមជាមុន ដោយសេរី និងបន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ នៅក្នុងដំណើរការធ្វើការសម្រេចចិត្តដែលប៉ះពាល់ដល់ពួកគេ និងជាពិសេសក្នុងការផ្ដល់ការយល់ព្រមលើគម្រោងអភិវឌ្ឍន៍លើដីរបស់ពួកគេ ។ គណៈកម្មាធិការក៏សម្ដែងការព្រួយបារម្ភរបស់ខ្លួនអំពីការការពារប្រកបដោយប្រសិទ្ធភាពចំពោះសហគមន៍ជនជាតិដើមភាគតិចក្នុងបរិបទនៃការរាតត្បាតនៃមេរោគកូវីដ-១៩ (មាត្រា ២ និង ២៦-២៧)។

៤៣. **រដ្ឋភាគីគួរ ៖**

**(ក) បង្កើត និងអនុម័តក្របខ័ណ្ឌច្បាប់ ដើម្បីទទួលស្គាល់ និងការពារសិទ្ធិជនជាតិដើមភាគតិច រួមទាំងនីតិវិធីសាមញ្ញសម្រាប់ការទទួលបានប័ណ្ណកម្មសិទ្ធិដីសមូហភាព។**

**(ខ) ធានាឱ្យបាននូវការពិគ្រោះយោបល់ពេញលេញ និងប្រកបដោយអត្ថន័យជាមួយជនជាតិដើមភាគតិច ក្នុងបញ្ហាទាក់ទងនឹងសិទ្ធិរបស់ពួកគេ ជាពិសេសសិទ្ធិក្នុងការយល់ព្រមជាមុន ដោយសេរី បន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ រួមទាំងនៅពេលផ្ដល់ការអនុញ្ញាតលើគម្រោងអភិវឌ្ឍន៍ដែលអាចប៉ះពាល់ដល់សិទ្ធិដីធ្លីរបស់ពួកគេ**

**(គ) បន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការទប់ស្កាត់ជម្លោះលើការប្រើប្រាស់ដីធ្លី រួមទាំងផ្ដល់ការធានាទាក់ទងនឹងដីដែលជនជាតិដើមភាគតិចកាន់កាប់ ឬជាម្ចាស់កម្មសិទ្ធិប្រពៃណី ។**

**(ឃ) ធានាថាជនជាតិដើមភាគតិចមិនត្រូវបានផ្លាស់ប្ដូរទីលំនៅដោយមិនអនុវត្តតាមការការពារផ្លូវច្បាប់ និងនីតិវិធីទាំងអស់ រួមទាំងការផ្ដល់ជម្រើសទទួលសំណងដែលគ្រប់គ្រាន់ និងមានជម្រើសអាចប្រៀបធៀបបាន។**

**(ង) ត្រូវប្រាកដថាក្នុងបរិបទនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ជនជាតិដើមភាគតិចមានសិទ្ធិទទួលបានព័ត៌មាន និងសេវាថែទាំសុខភាព រួមទាំងការធ្វើតេស្ដ ការព្យាបាល និងការទទួលបានវ៉ាក់សាំង។**

## ឃ. ការផ្សព្វផ្សាយ និងការតាមដាន

៤៤. រដ្ឋភាគីគួរផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវកតិកាសញ្ញា របាយការណ៍តាមកាលកំណត់ ជុំទីបី របស់ខ្លួន និងការសង្កេតសន្និដ្ឋានបច្ចុប្បន្ន ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិ ដែលមានចែងក្នុងកតិកាសញ្ញា ក្នុងចំណោមអាជ្ញាធរតុលាការ នីតិប្បញ្ញត្តិ និងរដ្ឋបាល សង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេស ព្រមទាំងប្រជាជនទូទៅផងដែរ។ រដ្ឋភាគីគួរធានាថារបាយការណ៍តាមកាលកំណត់ និងការសង្កេតសន្និដ្ឋានបច្ចុប្បន្ន ត្រូវបានបកប្រែទៅជាភាសាផ្លូវការរបស់រដ្ឋភាគី។

៤៥. អនុលោមតាមវិធាន ៧៥ (១) នៃវិធាននីតិវិធីរបស់គណៈកម្មាធិការ រដ្ឋភាគីត្រូវបានស្នើសុំឱ្យផ្តល់នៅត្រឹមថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៥ នូវព័ត៌មានស្តីពីការអនុវត្តអនុសាសន៍ ដែលធ្វើឡើងដោយគណៈកម្មាធិការក្នុងកថាខណ្ឌទី៩ (អំពើពុករលួយ) កថាខណ្ឌទី៣៥ (សេរីភាពនៃការបញ្ចេញមតិ) និងកថាខណ្ឌទី៣៩ (ការចូលរួមនយោបាយ) ខាងលើ។

៤៦. ស្របតាមវដ្តនៃការត្រួតពិនិត្យដែលអាចព្យាករណ៍បានរបស់គណៈកម្មាធិការ នៅឆ្នាំ២០២៨ មុនពេលដាក់របាយការណ៍ រដ្ឋភាគីនឹងទទួលបាននូវបញ្ជីបញ្ហារបស់គណៈកម្មាធិការ និងក្នុងរយៈពេលមួយឆ្នាំ រដ្ឋភាគីត្រូវបានរំពឹងថានឹងដាក់ជូនការឆ្លើយតបរបស់ខ្លួនចំពោះបញ្ជីបញ្ហា ដែលនេះនឹងបង្កើតបានជារបាយការណ៍តាមកាលកំណត់ជុំទីបួនរបស់ខ្លួន។ ក្នុងការរៀបចំរបាយការណ៍នេះ គណៈកម្មាធិការក៏ស្នើឱ្យរដ្ឋភាគី ពិគ្រោះយោបល់ឱ្យបានទូលំទូលាយជាមួយសង្គមស៊ីវិល និងអង្គការក្រៅរដ្ឋាភិបាល ដែលកំពុងប្រតិបត្តិការនៅក្នុងប្រទេស។ យោងតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ៦៨/២៦៨ ចំនួនកំណត់ពាក្យសម្រាប់របាយការណ៍គឺ ២១ ២០០ ពាក្យ។ ការសន្ទនាក្នុងន័យស្ថាបនាជាមួយរដ្ឋភាគី នឹងប្រព្រឹត្តទៅនៅឆ្នាំ២០៣០ នៅទីក្រុងហ្សឺណែវ។